បង្ហាត់បង្រៀនឲ្យចេះគន់មតិផ្សេងៗ ត្រូវជ្រើសរើសសៀវភៅល្អពីបណ្ណាល័យ ទាំងត្រូវមើលផងទាំងកាសែតដែលល្អសុចរិត គឺថាត្រូវអប់រំវិជ្ជារបស់ខ្លួន ឲ្យទៅជាគ្រូសាស្ដាគេបាន ។

២ – ត្រូវជ្រើសរើសមុខការ ឲ្យសមនឹងចំណេះវិជ្ជាខ្លួន ទាំងសមទៅតាមលក្ខណសម្បត្តិរបស់មាតាបិតាខ្លួន ។

អធិប្បាយថា៖ កុលបុត្រនោះត្រូវតាំងខ្លួនជាអ្នកស្លូតត្រង់ល្អ ឧស្សាហ៍ ចូលចិត្ត ខ្មៀតរៀន ស្ដាប់បង្គាប់របស់ចៅហ្វាយនាយជាដរាប, ព្យាយាមរៀនក្នុងមុខក្រសួងខ្លួន ដើម្បីឲ្យទៅជាកម្មករយ៉ាងចំណាន ហើយនឹងបានទៅជានាយល្អក្នុងអនាគត ។

៣ – កុលបុត្រត្រូវប្រាស្រ័យសេចក្ដីល្អជាមួយនឹងគ្រូគនខ្លួន ។

អធិប្បាយថា៖ បើមានសមាគមមិត្តចាស់ដែលបានរៀនរួមគ្រូជាមួយគ្នា, ខ្លួនកុលបុត្រឯងត្រូវចូលទៅជាបក្សពួកក្នុងចំណោមនោះឲ្យបានជាប់លាប់, ត្រូវចូលទៅក្នុងសមាគម រួបរួមជាមួយនឹងមិត្តភក្ដិចាស់របស់ខ្លួនក្នុងការកំសាន្តសប្បាយ ទាំងថែទាំទម្លាប់ល្អដែលបានរៀនមកពីគ្រូ ។ ដូច្នេះទើបមិនទៅជាមនុស្សអនាថា

ឯកឯងក្រៅចំណោមក្នុងការរស់នៅនោះទេ ។

កូនសិស្សល្អមិនភ្លេចគុណគ្រូដែលបានបង្រៀនខ្លួនឲ្យបានភាពជាកូនសិស្សល្អ ខំស្វាហ៍ទៅមកដោយរីករាយដើម្បីសួរសុខទុក្ខគ្រូរបស់ខ្លួន ដើម្បីពិគ្រោះការ សូមដំបូន្មាន ស្តាប់ពាក្យឱវាទនិងសេចក្តីយល់ឃើញរបស់គ្រូ ។ វាតែងតែទៅមកកាន់ទីលំនៅដើមរបស់វាដែលធ្លាប់ទៅមកពីក្មេង ។

## ភាសិត-បិដ្ក

បើឯងនៅរស់ដរាបណា ត្រូវតែស្វែងរកវិជ្ជាដរាបនោះ ។

សេចក្តីល្ងង់ខ្លៅមានច្រើនលើបុគ្គលណា បុគ្គលនោះមើលមិនឃើញវែងឆ្ងាយ ។

ការអានច្រើនមិនប្រសើរជាងអាននាំមកនូវប្រយោជន៍ ។

សៀវភៅទាំងឡាយជាគ្រឿងឧបត្ថម្ភព្រលឹងដូចជាម្ហូបអាហារដែលចិញ្ចឹមខ្លួនដែរ ។

ក្រោយដែលឈប់ធ្វើការ ការឈប់សម្រាកជាឱកាសល្អ ។

មុខការរកស៊ីគ្រប់ចំពូកសុទ្ធតែល្អ បើគេយកចិត្តទុកដាក់ក្នុង

ការនោះ ៗ ។

# វិធីហាត់មើល

## លាចាកសាលា

## Adieu à l'école

យើងត្រូវទុកសាលារៀន ជាកក្តីរបស់ការបង្ហាត់បង្រៀន, យើងមិនត្រូវភ្លេចថាសាលារៀននេះ ជាកូនសោដែលបានបើកបញ្ញា ទាំងជាគ្រឿងឧបត្ថម្ភវិជ្ជាដ៏ខ្ពង់ខ្ពស់របស់យើង ។

វិទ្ធីរឿង! ឆ្នាំផុតហើយ ឯងជិតនឹងបែកចេញឆ្ងាយពីគ្រូនិងគូកនឯង; យើងសុំឲ្យដំណឹងព្រួយនេះដល់ឯង, ដ្បិតថាការបែកគ្នានេះមិនមែនមានតែត្រឹមកំឡុង២ឬ៣ខែនោះទេ គឺជាការបែករហូត!

បិតាឯង ដោយហេតុដែលមានទាក់ទងនឹងការងាររបស់គាត់ៗ ត្រូវចេញពីភូមិតាំងឫស្សី ទៅឯកោះខ្សាច់កណ្តាល ។ យើងជាកូនចៅទាំងអស់គ្នា ក៏ត្រូវទៅជាមួយនឹងគាត់, ពុំទេ? យើងត្រូវទៅនៅវេលារដូវរំហើយនេះ ។

ចំណែកខ្លួនឯង ត្រូវចូលទៅបំពេញវិជ្ជាឯសាលាថ្មីទៀត ។

នែវិទ្ធិរៀន! ឯងនឹងលំបាកចិត្ត! យើងដឹងជាក់ថាឯងមានភក្តីស្រឡាញ់សាលាចាស់ ដែលក្នុងកំឡុង៤ឆ្នាំ ឯងបានធ្វើការ២ដងក្នុង១ថ្ងៃ ដែលឯងធ្លាប់តែបានឃើញមុខមិត្រភក្តិ មុខគ្រូដដែលៗ ហើយនឹងមាតាបិតាបងប្អូនឯង ដែលធ្លាប់តែទន្ទឹងចាំមើលផ្លូវឯងមកពីសាលារៀនដោយមុខស្រស់ញញឹម ៗ

នៅទីសាលារៀនចាស់នេះហើយ ដែលឯងធ្លាប់បានទទួលវិជ្ជា ធ្លាប់បានជួបប្រទះមិត្រភក្តិដ៏ច្រើន ធ្លាប់តែឮសំដីល្អ ៗ ដូច្នេះចូរឯងដក់ពាំយកពត៌មាននេះទុកជាអនុស្សាវរីយ៍ ដោយពេលវាចាដ៏ផ្អែមល្ហែមជាទីចុបចិត្តគូកនទាំងឡាយរបស់ឯង ៗ អស់ទាំងមិត្រភក្តិទាំងអស់គ្នានេះ ស្ទុះសឹងតែមានការជួបប្រទះនឹងសេចក្តីទុក្ខមិនខាន : ខ្លះមាតាបិតាស្លាប់ចោលទៅនៅកំព្រាតែឯងតាំងពីតូចមក. ខ្លះជាអ្នកក្រលំបាកតាំងពីក្មេង ៗ តែអ្នកទាំងអស់នេះមុខជានឹងបានទៅជាកម្មករយ៉ាងចំណាន, នឹងទៅជាមេបាគេ, ជាអ្នកធ្វើការរកស៊ី នឹងជាអ្នកដែលគេគួរគោរព ៗ បណ្តាគូកនឯងទាំងនេះ មិនលែងមាននរណាមួយដែលនឹងទៅជាមនុស្សធ្វើប្រទេសជាតិមាតុភូមិ

ឲ្យបានចំរើន ហើយនឹងបានទទួលសេចក្ដីដំកុំដំកើង ទៅជាមនុស្ស ល្បីល្បាញរបស់ប្រទេសជាតិឡើយ ។ ចូរឯងលាកលាចេញពី មិត្តភក្តិឯង ដោយទុកព្រលឹងឯងក្នុងគ្រួសារដ៏ថ្កុំថ្កើងនេះចុះ ។

ឱរិទ្ធិវៀង ! សាលារៀនទុកដូចជាមាតាដែលបានទទួលពីដៃ ដ៏ទន់ភ្លន់នៃយើងជាម្ដាយ កាលឯងទើបនឹងចេះនិយាយឡិកឡក់នៅ ឡើយ, សាលានេះហើយ ដែលធ្វើឲ្យម្ដាយពេញចិត្តរកអ្វីប្រៀបធៀប ស្មើពុំបាន ។ ដូច្នេះចូរឯងកុំភ្លេចសាលារៀននេះឲ្យសោះ ។ ឱកូន មាសម្ដាយអើយ ! ដល់ឯងធំឡើង ឯងនឹងធ្វើដំណើរទៅមើលជុំវិញ សាកលលោក, ឯងនឹងធ្វើទស្សនាការប្រទេស ក្រុង គេហដ្ឋាន ប្រាសាទ ទីសួនច្បារ ព្រៃព្រឹក្សាដ៏មានម្លប់ត្រឈឹងត្រឈៃ នាំឲ្យ ឯងរលឹកឃើញទីកន្លែងចាស់ដែលឯងធ្លាប់អប់រំវិជ្ជាដំបូងរបស់ឯង ។

## ពាក្យពន្យល់

អានសារពត៌មានដែលមានប្រយោជន៍ ន. គឺមើលត្រូវទៅ លើពាក្យសំដីប្រកបដោយប្រយោជន៍ ។

ព្រលឹង (âme) ន. ដំណើរជីវិត, ស្មារតី, វិញ្ញាណ, សេចក្ដីបំរែខ, ព្រលឹងព្រលះ, បាត់ព្រលឹង, បាត់វិញ្ញាណ ។

ព្រលឹង គុ. ដែលមានស្រីសួស្ដី; ដែលជាទីស្រឡាញ់, មានថ្ងៃថ្ងៃ, មនុស្សជាទីស្រឡាញ់, ប្អូនព្រលឹង ។

ចោទសួរ— ក្រោយដែលបានឈប់រៀនចេញពីសាលាទៅហើយ ក្មេងត្រូវឈប់រៀនសូត្រឬដូចម្ដេច ? ត្រូវធ្វើដូចម្ដេចឲ្យបានបន្តវិជ្ជាទៅមុខទៀតបាន? អ្នកត្រូវជ្រើសរើសមុខការងាររបស់អ្នកដូចម្ដេច? ត្រូវប្រព្រឹត្តដូចម្ដេចនៅវេលាដែលកំពុងរៀនប្រកបការងារនោះ? អ្នកត្រូវប្រាស្រ័យនឹងគ្នាដូចម្ដេចខ្លះ? ត្រូវចូលទៅក្នុងសង្គមណា? ត្រូវប្រាស្រ័យនឹងមិត្រភ័ក្ដិបាប់ដូចម្ដេច ?

## ការបញ្ជាក់ឡើងវិញ, ការដាក់ឲ្យធ្វើ

១- យើងត្រូវប្រព្រឹត្តដូចម្ដេចចំពោះគ្រូបាធ្យាយ ? ចូរពន្យល់ហេតុ ?

២- អ្នកធ្លាប់បានសំដែងទឹកចិត្តដ៏ស្មោះស្ម័គ្រពប់រកនឹងកតញ្ញូចំពោះគ្រូអ្នកដូចម្ដេចខ្លះហើយឬ ?

៣- កុមារសុខបានត្អូញត្អែរពីខ្លួនវាដែលទទួលទណ្ឌកម្មពីគ្រូវា ។

ចូរអ្នកពន្យល់វាពីឧបាយដែលនាំមិនឲ្យមានទោសកំហុសនោះផង ។

៤. នៅវេលាដើមឆ្នាំចូលរៀន អ្នកតែងគិតពីអនាគតរបស់អ្នក តើអ្នកត្រូវប្រារព្ធការនោះ ដូចម្ដេច ?

៥. នៅក្នុងកន្លែងរៀនរបស់អ្នក មានគូកនអ្នក ២ នាក់; ម្នាក់នោះមានប្រាជ្ញាវាងវៃគ្រាន់បើ តែពុំសូវប្រឹងប្រែងក្នុងការរៀន; ម្នាក់ទៀតអាប់ឧនពុំសូវឆ្លាតទេ តែមានព្យាយាមក្នុងកិច្ចការរបស់វា; តើអនាគតអ្នកទាំងពីរនាក់នេះនឹងទៅជាដូចម្ដេច ?

៦. អ្នកយល់ដូចម្ដេច បើគូកនអ្នកម្នាក់ នៅវេលាគ្រូដាក់ឲ្យធ្វើក្នុងការប្រឡង វាចម្លងតាមសៀវភៅយកទៅឲ្យគ្រូមើលដើម្បីដែងយកកន្លែងទី ១ ?

៧. ប្រយោជន៍អ្វីខ្លះដែលអ្នកត្រូវធ្វើចំពោះគូកនអ្នក, ១ នៅក្នុងសាលារៀន, ២ នៅវេលាចេញសម្រាកលេង, ៣ នៅក្រៅសាលារៀន ?

៨. សៀវភៅណាខ្លះដែលអ្នកគាប់ចិត្តមើល ? ចូរពោលពីហេតុដែលនាំឲ្យអ្នកចូលចិត្ត ។

៩- មិត្តភក្តិអ្នកម្នាក់ ដែលឈប់រៀន ចេញពីសាលាទៅហើយ សំគាល់ថាខ្លួនវាចេះដឹងហើយ ថាវាគិតមិនចេះភាន់ច្រឡំទេ, ចូរអ្នកសរសេរសំបុត្រទៅវា ពន្យល់វាថា មិនត្រូវលះបង់ការរៀនសូត្រទេ គួរតែព្យាយាមរៀនទៅទៀត ដើម្បីធ្វើខ្លួនឲ្យទៅជាកម្មករដ៏ល្អ ។

១០- សម្លាញ់អ្នកម្នាក់មានទម្លាប់តិះដៀលគូកនា ; អ្នកត្រូវជួយកែគំនិតវាដូចម្ដេច ? (រំលឹកវាតាមភាសិតអ្នកប្រាជ្ញបុរាណភាសិតខ្លះ) ។

## ជំពូកទី ៤

## Chapitre 4

# ករណីយកិច្ចផ្ទាល់ខ្លួន

# Devoirs personnels

## នាទីរបស់ចិត្ត (វិញ្ញាណ)

## Devoirs envers l'âme

### មេរៀនទី២១ សុចរិតទៀងត្រង់ កុហក ពុតត្បុត

### Sincérité, Mensonge, Hypocrisie

១-មនុស្សទៀងត្រង់តែងស្រឡាញ់សេចក្ដីសុចរិតលើសលប់, មនុស្សស្លូតត្រង់ មិនជ (បំភាន់) ខ្លួនឯង ដោយការបិទភ្នែក នឹងការបិទគុណវិបត្តិ (កំហុស) របស់ខ្លួន, ទាំងមិនបំភាន់អ្នកដទៃឲ្យខូចគុណធម៌ ។

អធិប្បាយថា: ការទាក់ទងទៅវិញទៅមករវាងមនុស្សនឹងមនុស្ស នៅលើសេចក្ដីទុកចិត្តដែលមនុស្សនីមួយ ៗ និយាយទៅតាមសេចក្ដីសុចរិត គឺគ្រប់ពេលណាក៏ដោយ និយាយតែពីខាងការពិតការមែនៗ ដូច្នេះ អ្នកផងដែលស្គាល់ថាជាមនុស្សសុចរិតស្លូតត្រង់ គេតែងតែ

ទុកចិត្តស្រឡាញ់ដោយស្មោះស្ម័គ្រ ។ ចិត្ត (វិញ្ញាណ) របស់មនុស្ស ប្រៀបដូចជាទឹកថ្លាក្នុងបឹងមួយ ដែលឆ្លុះភ្លឺចិញ្ចាចចិញ្ចែងចាំងទៅលើមេឃដ៏ទៀងស្រឡះ ដោយការបរិសុទ្ធិរបស់ខ្លួន ហើយបណ្ដាលឲ្យឃើញចំពោះចិត្តអ្នកចាំងឮដូចជាពេជ្រ ឬកែវមណីយ៉ាងប្រសើរ ។

២ - ចំណែកមនុស្សកុហកតែងពោលពាក្យមុសាវាទ ជួយនឹងពាក្យសុចរិត ដើម្បីចៀសវាងទោសក៏មាន ដើម្បីទម្លាក់ទោសទៅលើគេក៏មាន ដើម្បីអួតអាងក៏មាន ដោយគិតថាខ្លួនជាអ្នកមានបញ្ញាគ្រាន់បើដែលមិនមែនជាកិរិយាត្រឹមត្រូវសោះ ។

អធិប្បាយថា: មនុស្សដែលមានគំនិតអាក្រាទ ខូចខិល ជាមនុស្សដែលគេគិះដៀល រមែងជាប់ចោទក្នុងរឿងរ៉ាវផ្សេង ៗ ជាមនុស្សកុហក ។ មិនយូរប៉ុន្មានទេមុខជាជាប់អន្ទាក់របស់ខ្លួនឯងដោយគេដេញដោលរកខុសត្រូវទៅ ទើបទាល់ច្រើយតបប ។ មនុស្សបែបនេះ បើទុកជានិយាយត្រង់ក៏គេមិនជឿ ។

៣ – មនុស្សមានពុតត្បុតករឹងរិតតែដូជាតិទៅទៀត, តែងបិទ

បាំងភាសាអាក្រក់, បញ្ចេញគុណធម៌ល្អ ហើយតែងតែគិតបំភាន់
អ្នកជិតខាងខ្លួន ។

អធិប្បាយថា : , កូនសិស្សមានពុតត្បុត ធ្វើហាក់ដូចជាអ្នក
គោរពប្រតិបត្តិគ្រូរបស់វា ហើយធ្វើឲ្យគ្រូទុកចិត្តវា, ប៉ុន្តែខាង
ក្រោយខ្នង វាចាក់រុកអស់ទាំងគូកនវាឲ្យទៅជាសត្រូវនឹងគ្រូ ។ ក្មេង
មានពុត ក្នុងកណ្ដាលបំណាម ធ្វើអាកប្បកិរិយាឲ្យគេអាណិត,
ប៉ុន្តែការរស់នៅសម្ងាត់របស់វា ជាមនុស្សគ្មានគុណធម៌មានមេត្តា
ជាដើមឡើយ ។ វាប្រើអាការប្រចុបចំពោះមុខមិត្តភក្តិ, តែ
គូកនវាខ្លះដែលជាអ្នកប្រៃណាន ក្រើននិយាយដើមពីវា កាល
ដែលវាចេញផុតទៅ ។ កិរិយាពុតត្បុតជាទោសយ៉ាងអាក្រក់ ។

៤ — កុលបុត្រទាំងឡាយចូរជាអ្នកស្លូតត្រង់ ចូរជាអ្នកចេះ
លន់តួ ទាំងស្គាល់ទោសរបស់ខ្លួន ។

អធិប្បាយថា : សេចក្ដីលន់តួជាការពង្រីកសេចក្ដីស្រឡាញ់
របស់មាតាបិតានឹងគ្រូអាចារ្យ ហើយតែងបានទទួលសេចក្ដីអត់
ទុន ។ យើងមិនត្រូវធ្វើជំទាស់នឹងចិន្តារបស់យើង ; ត្រូវតែនិយាយ

ដោយសុចរិតពិតត្រង់, តែគេមិនបង្ខំឲ្យនិយាយទាំងអស់នោះទេ ។ មែនពិតការពោលសុចរិតពិតត្រង់ជាពាក្យពីរោះ, តែការពិតត្រង់នេះ មិនត្រូវនិយាយទាំងអស់ទេ, សមនឹងពាក្យភាសិតថា "ពាក្យពិតរែងស្អែង" ។

សំនួរ:- មនុស្សសុចរិតសំដែងអាការគោរព ចំពោះការពិតត្រង់ដូចម្ដេច? ចិត្តមនុស្សសុចរិតដូចជាអ្វី? ដូចម្ដេចហៅថាមនុស្សកុហក? មនុស្សភូតភរដូចណាត្រូវទទួលទណ្ឌកម្ម ព្រោះហេតុអ្វី? ដូចម្ដេចហៅថាមនុស្សមានពុតត្បុត? មនុស្សមានពុតត្បុតនេះណាក់ទោសភាដូចម្ដេច? ការពិតត្រង់ត្រូវតែបញ្ចេញនិយាយប្រាប់គេទាំងអស់ឬដូចម្ដេច?

## ភាសិត - ចិន្ដា - រឿងរ៉ាវ

មនុស្សសុចរិត គឺមនុស្សដែលពោលពាក្យប្រកបចិន្ដា នឹងដោយពាក្យត្រង់ ហើយនឹងដោយគុណធម៌ល្អ ។

ពុទ្ធសាសនាជាសាសនាពិតត្រង់បំផុត, ពុទ្ធបរិស័ទអ្នកប្រព្រឹត្តតាមសុទ្ធតែជាអ្នកពិតត្រង់ ។

មនុស្សដែលសំដែងទោសរបស់ខ្លួន មិនគួរនឹងទទួលនូវសេចក្ដីបន្ទោសឡើយ ។

ពោលពាក្យកុហក ដើម្បីឲ្យគេអត់ទោសឲ្យ ដូចជាយកទឹកខ្មៅទៅលាងខ្លួន ។

មនុស្សមានពុតត្បុត គឺជាមនុស្សគ្មានគុណធម ដូចជាទន្សាយនឹងដូនចាស់ឡូលចេក ។

# រឿងទន្សាយនឹងដូនចាស់

ថ្ងៃមួយ ទន្សាយត្រូវសេចក្ដីស្រេកឃ្លានគ្របសង្កត់ ក៏ធ្វើពុតជាដេកស្លាប់នៅក្បែរផ្លូវថ្នាមួយ ដែលមនុស្សតែងតែដើរទៅមក ។ ថ្ងៃនពីដូនចាស់ម្នាក់ ឡូលចេកទុំមួយល្អីដើរមកតាមផ្លូវនោះ ក្រឡេកភ្នែកទៅឃើញទន្សាយដេកស្តូក ដូចជាស្លាប់ ក៏មានសេចក្ដីត្រេកអរថា នឹងបានទន្សាយយកទៅស្ងោរគោត ក៏លើកទន្សាយដាក់លើទ្រឡូលចេកទុំ ហើយក៏ម្នីម្នាដើរសំដៅទៅឯផ្ទះខ្លួន, ដល់ទៅមាត់ច្រកផ្ទះខ្លួន ក៏ស្រែកហៅតាចាស់ជាប្ដីឲ្យមកទទួលទ្រឡូល ។ ដូនចាស់ក្រឡេកមើលទ្រឡូលខ្លួនក៏ស្រាប់តែពុំឃើញទន្សាយ ព្រោះវាលបលោតចុះទៅ ចេកទុំក៏អស់រលីងពីល្អី ហើយក៏គក់ទ្រូងទឹកភ្នែកខ្លាសខឹងនឹងចាញ់បោកទន្សាយដែលមានពុត ។

# ពន្យលពាក្យ

គុណធម៌ ន. ធម៌ដែលមានដំណើរចំរើនតាមជាន់តាមថ្នាក់, សេចក្តីល្អ, សេចក្តីបរិសុទ្ធិ... ។

បិត្តា ន. សេចក្តីគិត (គំនិត) ។ បើជាពាក្យរាជសព្ទវិញថា ទ្រង់ព្រះចិត្តា គឺទ្រង់គិត, ទ្រង់រិះគិត ។

យកទឹកខ្មៅទៅហេងខ្លួន កិ. ន. ធ្វើខ្លួនឲ្យរឹងរិតតែប្រឡាក់ថែម គឺធ្វើខ្លួនឲ្យរឹតតែអាក្រក់ ។

ទន្សាយ ន. សត្វចតុប្បាទ ធំជាងសត្វឆ្មាបន្តិច ជាសត្វរត់លឿន ល្បីល្បាញថាជាសត្វមានប្រាជ្ញា ។

ដូនចាស់ ន. យាយចាស់ គឺមនុស្សស្រីមានវ័យជ្រេន ។

ដេកស្លូក កិ. កិរិ. សម្រេចឥរិយាបថមួយផ្សេង គឺដាក់ខ្លួនផ្តេក លើ ... ។ ដេកស្លូក គឺដេកដូចជាគេស្លាប់ ។

# វិធីហាត់អាន

## កាំបិតរបស់ជ័យ

កុមារជ័យដែលបានឡើងជាឧកញ៉ាចៅហ្វាយខេត្តបាភ្នំ កាលនៅពីកុមារតូច គេបានឲ្យរង្វាន់ជាកាំបិតមួយ ។ កុមារនេះកាលដែលទទួលកាំបិតហើយ គ្មានទឹកនាអ្វីក្រៅពីចង់កាប់លេងសប្បាយអស់ទាំងដើមឈើក្នុងសួនច្បារ ដើម្បីសាកល្បងមើលនូវអាវុធថ្មីរបស់ខ្លួនទេ ។ ស្មៅក្ដី ឈើក្ដី វល្លិ៍ក្ដី មែកឈើក្ដី ដែលទើសមុខវាទាំងប៉ុន្មាន វាកាត់កាប់ឥតគិតដោយសប្បាយ រហូតដល់កាប់ពុះដើមក្រូចពោធិ៍សាត់ ១ ដើម ដែលជាទីស្រឡាញ់របស់ឪពុកវា ។ លុះបិតាឃើញដូច្នោះ ក៏ខឹងហើយសួររកមុខអ្នកបំផ្លាញ ; តែគ្មានអ្នកណាដឹង ។ លុះមួយស្របក់ បិតានេះ ក៏សង្ស័យលើកុមារជ័យជាកូនហើយបានសាកសួរតាមដំណើរ ដើម្បីនឹងធ្វើទោសឲ្យរាងចាលកុំឲ្យប្រព្រឹត្តដូច្នោះតទៅទៀត ។ កុមារជ័យមានសេចក្ដីតក់ស្លុតជាពន្លឹក ។ វានៅស្ងៀមទ្រឹងគិតមួយស្របក់ រួចក៏ឆ្លើយដោយភាពជាអ្នកត្រង់ល្អទៅនឹងឪពុកវាថា "លោកឪពុក, ខ្ញុំមិនពោលពាក្យ

មុសាវាទទេ, គឺខ្ញុំហ្នឹងឯងជាអ្នកបំផ្លាញដើមឈើនេះ ដោយកាំបិតខ្ញុំ: សូមឲ្យលោកឪពុកដាក់ទណ្ឌកម្មខ្ញុំចុះ ។ ឪពុកកុមារដ័យក៏ស្រែកថា ឱកូន! ឯងចូរមក; ឪពុកទឹងត្រកងបី, ឯងធ្វើខុសដោយកាប់ដើមក្រូចនេះ, តែសេចក្ដីត្រង់របស់ឯង នាំឲ្យមានតម្លៃថ្លៃជាងដើមក្រូចទាំងប៉ុន្មាននៅលើផែនដីដែលបញ្ចេញផ្កាមកជាប្រាក់ ផ្លែមកជាមាស; ដូច្នេះចូរកូនឯងថែរក្សារឿងពិតត្រង់នេះទុកជាអនុស្សាវរីយ៍ក្នុងការរស់នៅរបស់ឯង ។ នេះជាសេចក្ដីពិតត្រង់ ។

## ពាក្យពន្យល់

ឧកញ៉ា ន. ពាក្យប្រើជាឋានន្តរស័ក្ដិនៃមន្ត្រីថ្នាក់ខ្ពស់ជាងទីព្រះ, សំដៅសេចក្ដីថា "អ្នកចេះត្រួតត្រាមុខការក្នុងក្រសួង ឬនាទីរបស់ខ្លួន" (មកពីពាក្យខ្មែរ ឧកឬអុក "ត្រួតត្រាពេញអំណាច" + ម. ញ៉ា "ដឹង, ចេះ ស្គាល់") ប្រើតាមលំដាប់ថ្នាក់ស័ក្ដិធំតូចថា លោកអ្នកឧកញ៉ា... អ្នកឧកញ៉ា... ។

មុសាវាទ ន. ពាក្យកុហក ។

ផ្កាជាប្រាក់ ផ្លែជាមាស ន. គុ. គឺសេចក្ដីប្រៀបធៀបផ្កា

នឹងផ្លែក្រូចពោធិ៍សាត់ទៅនឹងប្រាក់មាសដែលជារបស់ថ្លៃថ្នូរ ។

## ការអាន

### តាបសកុហក

មានសេចក្ដីដំណាលថា មានតាបសម្នាក់ធ្វើស្មឹងស្មាធិ៍អាស្រ័យនៅនាញកភ្នំមួយ ។ មានអ្នកស្រុកជិតខាងតែងចាំទុកបំរុងតាបសនោះដោយស្រឡាញ់នឹងគោរព ។ ថ្ងៃមួយ អ្នកឧបត្ថម្ភយល់ឃើញថា ផ្ទះខ្លួនពុំសូវគត់មត់ ហើយដោយការទុកចិត្តលើតាបសនេះដូចជាឪពុកបង្កើត ក៏យកមាសពេជ្រទៅផ្ញើនឹងតាបស ។ តាបសធ្វើហាក់ដូចជាមិនចង់ទទួល ពោលតបទៅវិញថា អាត្មាជាអ្នកធ្វើសមណធម៌ គ្មានពេលនឹងថែរក្សាទ្រព្យទាំងអស់នេះទេ, ប៉ុន្តែបើចង់ទុក, ត្រូវបិទស្លាកហើយជីកដីកប់ទុកខ្លួនឯងត្រង់នេះចុះ ។ ឧបដ្ឋាកនោះក៏ធ្វើតាមបង្គាប់រួចវិលទៅផ្ទះវិញ ។ ថ្ងៃពីតាបសមានពុតខូច លុះនៅយូរបន្តិចទៅក៏អផ្សុកគិតថា “អញបានទ្រព្យប៉ុណ្ណោះនឹងសឹកយកទៅចិញ្ចឹមខ្លួនបានបរិបូណ៌” ក៏គាស់អស់ទាំងកំណប់ទ្រព្យដែល

គេធ្វើទាំងប៉ុន្មានយកមករៀបជាបន្ទិចរួចស្រេច ក៏ហៅអ្នកម្ចាស់ទ្រព្យដែលផ្ញើមកប្រាប់ថា ឥឡូវអាត្មានឹងលាថយទៅធ្វើធម៌អាថ៌ឯទីដទៃ; ទ្រព្យរបស់អ្នកនៅទាំងអស់ឯទីដែលអ្នកកប់ទុកខ្លួនឯង ។ អ្នកម្ចាស់ទ្រព្យដោយសេចក្ដីទុកចិត្តក៏មិននឹកនាទីងនាំគ្នាទៅពិនិត្យទ្រព្យខ្លួនៗ បំណែកឯតាបស ដើម្បីសំដែងសេចក្ដីសុចរិតរបស់ខ្លួន នៅវេលាដែលចេញទៅបានបន្តិច ក៏ធ្វើជាត្រឡប់មកវិញ យកស្បូវមួយសរសៃដែលជាប់នៅនឹងផ្នួងសក់ខ្លួនមកឲ្យអ្នកម្ចាស់អាស្រម រួចវិលទៅវិញម្ដងទៀត ។ អ្នកម្ចាស់ទ្រព្យ បានទៅគាស់ទ្រព្យរបស់ខ្លួនរកពុំឃើញ ទើបទៅប្ដឹងពោធិសត្វ ។ លោកបានសាកសួរតាមដំណើរ ក៏ឲ្យទៅតាមចាប់យកតាបសនោះមកវិញ ពិចារណារកត្រាតែឃើញរបស់គ្រប់ទាំងអស់វិញ ។ អ្នកម្ចាស់ទ្រព្យនឹងអ្នកស្រុកក៏នាំគ្នាព្រួតវាយតាបសស្ទើរតែនឹងស្លាប់ ។

## ពន្យល់ពាក្យ

**តាបស** ន. អ្នកបួសខាងក្រៅពុទ្ធសាសនា កាន់ព្រហ្មចរិយធម៌

វៀរបាកមេថុនធម្ម ប្រព្រឹត្តកាន់តបៈ (ឥសី) ។

ឧបត្ថម្ភ ន. ការទំនុកបំរុង, គ្រឿងទំនុកបំរុង, ជួយឧបត្ថម្ភ ។

ពោធិសត្វ ន. អ្នកដែលមានចិត្ត ឬ មានសេចក្តីប្រាថ្នាជាប់ នៅក្នុងពោធិញាណបំរុងនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ , អ្នកមានប្រាជ្ញាកាត់វៀងរ៉ាវកសេចក្តីអាក្រក់ល្អ ។

## វិធីហាត់អាន មេសូត្រ

## តម្រាផោតដោយស្រវឹងឡើងបញ្ជោរ

## មនុស្សប្រប្រុបជាមនុស្សបោកប្រាស់

## ហេតុនេះគួរកុំទុកចិត្ត មនុស្សប្រប្រុប

(ពាក្យអានជាបទ) កាកគតិតែង ដំណាលដំណែង ដំណើរ បក្សា ក្អែកគោកមួយនៅ លើចុងរកា សែនសុខកាយា ពរពិត ឥតមោះ ។ ថ្ងៃមួយបក្សី ចេញស្វែងចំណី តាមភូមិកៀនគោះ ឃើញអ្នកទិគម ហាលទំពឹកដោះ ក្អែកអរហើរផ្លោះ ចុះចោះ ចឹកបាន ។ កាន់ស្ទាបហើរស្ទៅ ដំរង់ត្រង់ទៅ លំនៅស្នះសាន

ដល់ហើយចុះទំ ទ្រនំទៃព្រាណា បែរមើលទីឋាន ឋានដែល

យាត្រា ៗ កាលនោះមានសត្វ សំពោច ១ ឆាត់ ស្វែងរកគោត្តា

មកដល់យល់ក្អែក ទំមែករុក្ខា មាត់ពាំនំប្រា- កដជាចំណី ៗ

សំពោចគិតថា អញនឹងចរចា បញ្ជោរបក្សី ឲ្យវាហាមាត់ ក្អាត

ធ្លាក់ចំណី ជ្រុះមកដល់ដី បានអញវិញណា ៗ គិតហើយទើបពោល

ជាពាក្យបញ្ជោរ ទៅកាន់ក្អែកថា ក្អែកអើយអ្នកក្អែក រូបឯក

សោភា ចំពុះដូចជា ខ្ទង់កែវមរកដ ៗ ពេមស្លាបស្រស់ស្រិល

រលង់ដូចនិល រលើបប៉ត់បត់ ចង្កេះសមទ្រង់ ជង្គង់សមបទ

វង់មុខសមមាត់ សមមានលក្ខណា ៗ រូបអ្នកឧត្តម បើតាមក្បួនខ្ញុំ

ទំនាយទាយថា នឹងបានសម្រេច ជាស្តេចបក្សា តែសព្ទសាព

ពុំទាន់ប្រត្យក្ស ៗ បើសិនអ្នកស្រែក ខ្ញុំឮសម្រែក ស្បូសមចំសក្តិ

ខ្ញុំហ៊ានទំនាយ ទាយថាអ្នកដាក់ បានជាចមចក្រ កំពូលបក្សា ៗ

ក្អែកឡើងសំឡូត ឮគេសក្ខិត សរសើរអាត្មា ចង់ឲ្យគេស្តាប់ សូរ

សព្ទវាចា ទើបឈរឡើងហា មាត់ស្រែកចេញខ្លា ៗ ឯនំពាំនោះ

ធ្លាក់ពីចំពុះ ជ្រុះមកដល់ដី សំពោចស្ទុះស្រួល ទទួលចំណី

ហើយបែរស្រដី បំអកបកក្ប ៗ ក្អែកអើយចៅក្អែក អ្នកឯងបែងចែក

បំណើរនេះណា យើងពេញគាប់ចិត្ត ដ្បិតអ្នកយល់ថា យើងជាហោរា

ទទួលខាន់ទៅ ៗ ជាហើយចៅក្អែក ប្រព្រឹត្តនេះឯក ឥតមានហ្វង

សៅ អ្នកឯងទៅរក មកទៀតណាចៅ ពីថ្ងៃនេះទៅ យើងបាន

ពឹងផង ៗ ថាហើយសំរោច បែរប្រាណស្ទុះផ្លុត ចូលព្រៃដូចប៉ង

គាគោបង់នំ ក្រិបចិត្តកន្ទង ពុំដឹងទំនង ខ្លាចលងភក្ប ៗ

## ពន្យល់ពាក្យ

ក្អែកគោក ន. បក្សីមានសម្បុរខ្មៅ ដំណើរលោតៗ ច្រើនបរិភោគ អសុភជាអាហារ រកស៊ីលើគោក ៗ ក្អែកមានពីរយ៉ាង ក្អែកទឹករក ស៊ីក្នុងទឹក ៗ

សំពោច ន. សត្វចតុប្បាទ ពួកឈ្លុស មានក្លិនប្រហើរ; មានពីរយ៉ាងគឺ សំពោចដំណើប សំពោចខ្ញុយ, ជាសត្វត្រើចរ វេលាថ្ងៃ ពួនសម្ងំនៅក្នុងរូង ៗ

សព្ទសភា ន. សូរសម្លេង ៗ

ប្រត្យក្ស គុ. ឬ កិ. វិ. ដែលជាក់, ប្រាកដ ។

សង្អួត កិ. កួតឡើយ ៗ សរសើរឡើយ ៗ ។

អំនួត ន. ឡើងដោយគេសរសើរ, ការពោលអួត,

មនុស្សមានអំនួត មនុស្សអ្នកអួត ។

* * * *

## មេរៀនទី ២២ សុភាព ព្រហើន អួតអាង

## modestie - orgueil - vanité

១-ត្រូវស្គាល់ខ្លួនឯង ។ នេះជាគោលអ្នកមានកិរិយាសុភាពរៀបរយ ។ កាលណាគេស្គាល់ខ្លួនឯងពិតប្រាកដ គឺថាដឹងខ្លួនជាអ្នកមានកិរិយាល្អក្តី មិនល្អក្តី សេចក្តីស្គាល់ដឹងបែបនេះនាំឲ្យទៅជាមនុស្សសុភាពរាបសា ។

អធិប្បាយថា: មនុស្សគ្រប់រូបមិនមែនមានលក្ខណៈល្អព្រមទាំងអស់ទេ ។ តែមនុស្សនីមួយៗ ត្រូវការបង្កើតខ្លួនឲ្យទៅជាអ្នកល្អ ។ មានតែសេចក្តីសុភាពរាបសានេះឯងហើយដែលជាគុណធម៌របស់មនុស្សអ្នកថ្លៃថ្នូរ ។ មនុស្សល្ងង់និងមនុស្សលីលា

កម្រិតនឹងបានទៅជាមនុស្សសុភាពរាបសា, រាតែងតែទឹកស្មានហួស ពីលក្ខណៈរបស់ខ្លួន តែងតែនិយាយអួតអាងក្អេងក្អាងប្រឡោះប៉ោះៗ

២- មនុស្សព្រហើន គឺជាមនុស្សឈ្មានពាន ឥតមានសេចក្ដី គួរសមដល់ខ្លួនឯងនិងអ្នកដទៃ ។

អធិប្បាយថា មនុស្សព្រហើន លើកខ្លួនឯងស្មានថាជាមនុស្ស កំពូលគេ ជាអ្នកមានប្រាជ្ញា មានលក្ខណៈបរិបូណ៌ព្រម, ចង់ ឲ្យគេអួតសរសើរក្នុងការដែលខ្លួនធ្វើទាំងប៉ុន្មាន, មិនចង់ឲ្យនរណា មួយនិយាយជំទាស់នឹងខ្លួន ទាំងមិនចង់ទទួលកំហុសដែលខ្លួនធ្វើ ខុសនោះទេ ទាំងមិនចូលចិត្តតាមដម្បូន្មានល្អឡើយ ។ នៅទីបំផុត ទៅជាអត្តទត្តបុគ្គល (égoiste) ជាមនុស្សនៅម្នាក់ឯង ចូលហ្វូង បំណោមនឹងគេពុំបុះ ដោយគិតថា ក្នុងលោកនេះគ្មាននរណាស្មើ នឹងខ្លួន ។ មនុស្សព្រហើនតែងទទួលរងគ្រោះនឹងគេបន្ទុះបន្អាប់ កណ្ដាលហ្វូង ។

៣- មនុស្សអួតអាង គឺជាមនុស្សព្រហើនបន្ទាប់មកដែរ ។

អធិប្បាយថា: ជាមនុស្សអាងក្អាងដោយមានរូបពងខ្លួនល្អក្ដី

សំលៀកបំពាក់ឬធនធានរបស់ឪពុកម្ដាយក៏ក្ដី មានផ្ទះសំបែងល្អក្ដី ច្រើននិយាយតែពីព្រេងសំណាងនឹងការបានមានរបស់ ៗ បើបំណែកខាងស្ដ្រីក្រមុំវិញ សេចក្ដីអួតអាងចេញជាគ្រឿងអលង្ការ ជាអ្នកតែងខ្លួន ៗ គុណវិបត្តិបែបនេះ ( défants ) ជាការនាំឲ្យមានគ្រោះថ្នាក់ (dangereux ) ដោយធ្វើអាកប្បកិរិយាមិនត្រឹមត្រូវតាមភាពជាស្ត្រីភាព ៗ គួរតែលះបង់ចោលជាយ៉ាងប្រញាប់ ៗ

## វិធីហាត់អាន

### សត្វកណ្ដុរពីររូប

សេចក្ដីដំណាលថា មានសត្វកណ្ដុរ ១ មានសេចក្ដីអផ្សុកនឹងការរស់នៅក្នុងសេចក្ដីគ្រោះថ្នាក់ នឹងសេចក្ដីតក់ស្លុត ដោយមានសត្វឆ្មាទាំងឡាយចេះតែយាយី, ក៏បានហៅកណ្ដុរមួយរូបដែលអាស្រ័យនៅទៀបជិតខាងខ្លួននោះដែរ មកនិយាយថា “ អញបានគិតឃើញគំនិតល្អមួយថ្មីលេចឡើង ដោយអញបានអានសៀវភៅទាំងឡាយ ដឹងសេចក្ដីពីថ្ងៃមុនមកថា : មានស្រុកមួយជាស្រុកសប្បាយ គឺស្រុកឥណ្ឌៀ ដែលអ្នកស្រុកតែងរាប់អានឆ្មា បើងជាសត្វ

កណ្តុរ ; ការរស់នៅរបស់យើងក៏ទៀងជាស្រួលជាងទីនេះ ។ អ្នកស្រុកដែលធ្លាប់តែគោរពគេជឿថា ព្រលឹងរបស់សត្វកណ្តុរ កាលដើម ជាព្រលឹងរបស់មេទ័ពយ៉ាងធំ ឬព្រលឹង របស់ស្តេច ណា មួយ ហើយព្រលឹងរបស់កណ្តុរនេះ ។លុះស្លាប់ទៅក៏ត្រូវទៅបដិសន្ធិជារូបស្ត្រី ឬជាមនុស្សមានបុណ្យស័ក្តិធំ; ក្នុងមតិសៀវភៅទាំងឡាយនេះឃើញថា អស់ទាំងសត្វទាំងឡាយ អ្នកស្រុកប្រទេសនោះតែងសង្គ្រោះដូចជាបងប្អូនបង្កើត, មានមន្ទីរពេទ្យសម្រាប់កណ្តុរដែលគេចិញ្ចឹម ឲ្យបាយទឹកដូចជាមនុស្សដែរ; ដូច្នេះបងស្រី! ចូរយើងទៅកាន់ប្រទេសដ៏ល្អនោះជាមួយគ្នា ; នៅស្រុកនោះពួកកងក្រវែលប៉ូលិសក៏សុចរិតត្រឹមត្រូវ" ។

កណ្តុរដែលជាគូកន ដោយពុំបានគិតគូរ ក៏ព្រមព្រៀងគ្នាធ្វើដំណើរទៅជាមួយគ្នា ។ សត្វទាំងពីរក៏នាំគ្នាចុះកាន់សំពៅតាមស្ពានក្នុងវេលាល្ងាចដែលគេប្រុងប្រៀបផ្ទុកអីវ៉ាន់ ។

សំពៅក៏ចរចេញតាមផលសាធ្វើដំណើរយ៉ាងវែងឆ្ងាយ ។ កណ្តុរទាំងពីរសប្បាយពន់ពេកដោយបានឃើញសមុទ្រ ឆ្ងាយពី

ការរុកគួនរបស់ខ្លា ៗ ដំណើរតាមសមុទ្រនេះសប្បាយពន់ពេក ៗ សត្វកណ្ដុរទាំងពីរ កំបានចូលឡើងទៅដល់ទីក្រុងមួយឈ្មោះសាព៉ាត់ គឺពុំមែនស្វែងទៅរកសម្បត្តិទ្រព្យដូចជាអ្នកដំណើរទាំងពួងទេ គ្រាន់តែទៅដើម្បីឲ្យគេចិញ្ចឹមពចអានខ្លួនទាំងពីរនាក់ប៉ុណ្ណោះ ៗ លុះចូលទៅដល់ក្នុងផ្ទះ ១ ដែលជាកន្លែងសម្រាប់អស់ទាំងសត្វកណ្ដុរអាស្រ័យនៅ, កណ្ដុរ ១ កំនិយាយអួតខ្លួនថា ខ្លួនកាលពីដើមជាព្រាហ្មណ៍ម្នាក់មានល្បីឈ្មោះ នៅខាងស្រុកម៉ាល្វបា ដែលជាស្រុកនៅមាត់សមុទ្រ ៗ កណ្ដុរជាគូកនមួយទៀតនិយាយអួតថា ខ្លួនជាជំទាវខុនណាងម្នាក់ យ៉ាងល្អឯក មានស្លឹកត្រចៀកវែងៗ កណ្ដុរទាំងពីរនេះ អួតជ្រុលពេកនាំឲ្យសង្កៀរត្រចៀកកណ្ដុរស្រុកកង្គ ទាល់តែគេអត់ទ្រាំពុំបាន កំនាំគ្នាខាំសម្លាប់បង់ទៅហោង ៗ

រឿងនេះ បានសេចក្ដីជាគតិថា បុគ្គលដែលទៅឆ្ងាយដើម្បីចៀសវាងការគ្រោះថ្នាក់; តែបើមិនមានសុភាពរាបសារទេ, អ្នកនោះឯងតែងជួបប្រទះតែនឹងសេចក្ដីទុក្ខ ៗ

# ពន្យល់ពាក្យ

កណ្ដុរ ន. សត្វចតុប្បាទពួកមួយ ក្នុងពួកសត្វមានដោះ ជាសត្វ ឲ្យទុក្ខដល់មនុស្សដោយហេតុបំផ្លាញមានកាត់សំពត់អាវជាដើម ។

យាយី កិ. បៀតបៀន, រុកគួន ។

ប្រទេសឥណ្ឌា ន. ប្រទេសមួយធំ ផែកខាងអាស៊ីទ្វីប នៅខាងជើងថៃខាងលិចប្រទេសកម្ពុជា ជាស្រុកកំណើតដែលកើតព្រះពុទ្ធសាសនា ។

ជិតារីខុនណាង ន. ពាក្យជាឈ្មោះនៃស្រីជាភរិយាសេនាបតី ដែលព្រះរាជាតាំងប្រទានឲ្យ ។

ចោទសួរ ៈ គោលសំខាន់សេចក្ដីសុភាពរាបសារដូចម្ដេច ? ដូចម្ដេចហៅថាមនុស្សព្រហើន? វាប្រព្រឹត្តដូចម្ដេច ? មនុស្សល្ងង់រឹងសំណាធ្វើខ្លួនឲ្យទៅជាមនុស្សសុភាពបានឬទេ ? ដូចម្ដេចហៅថាមនុស្សអួតអាង ? ស្ដីអួតអាងសំដែងអាការដូចម្ដេចខ្លះ? អ្នកត្រូវធ្វើដូចម្ដេចចំពោះមនុស្សព្រហើន ?

* * * *

## មេរៀន ២៣ សេចក្ដីក្លាហាន

## សេចក្ដីក្លាហានមានប៉ុន្មានយ៉ាង?

**Le courage Ses différentes formes**

អ្វីហៅថា សេចក្ដីក្លាហាន? សេចក្ដីក្លាហាន គឺសេចក្ដីមិនខ្លាចឈឺចាប់ ហើយនឹងសេចក្ដីផ្ចាញ់ផ្ចាលឲ្យឈ្នះសេចក្ដីខ្លាច ។ បើខ្ញុំមានជម្ងឺហើយ ត្រូវពេទ្យវះកាត់ ត្រូវដេកទ្រាំជម្ងឺនៅនឹងមួយកន្លែងជាច្រើនសប្ដាហ៍ដោយឥតត្អូញត្អែរ នោះគេនឹងសន្មតថា ខ្ញុំមានសេចក្ដីក្លាហាន ។ គ្រូពេទ្យដែលដឹងថា បើនឹងទៅមើលមនុស្សមានជម្ងឺធ្ងន់ ដូចជាជម្ងឺអាសន្នរោគនឹងជម្ងឺពិសជាដើម អាចឲ្យមានគ្រោះថ្នាក់ដល់ជីវិត ហើយខំកាត់ចិត្តទៅថែរក្សាអ្នកជម្ងឺនោះ ៗ គ្រូពេទ្យនោះក៏គេត្រូវចាត់ថា មានសេចក្ដីក្លាហានដែរ ។ សេចក្ដីខ្លាចបណ្ដាលមកអំពីធាតុកម្មនៃរាងកាយរបស់យើង គឺថារាងកាយជារបស់ញាប់ញ័រជាមុន ទើបមានសេចក្ដីខ្លាចជាក្រោយ ។ បើយើងបំបាត់សេចក្ដីញាប់ញ័រក្នុងរាងកាយយើងចេញបាន, ទើបយើងមិនមានសេចក្ដីខ្លាច ។

ក្រៅអំពីសេចក្ដីខ្លាចដែលបណ្ដាលមកអំពីកាយ មានសេចក្ដីខ្លាចមួយយ៉ាងទៀត ដែលបណ្ដាលតាមផ្លូវចិត្ត នេះក៏មិនមានអ្វីប្លែកទេ គឺមកពីញាប់ញ័រក្នុងខ្លួនជាដំបូងដែរ ។

សេចក្ដីក្លាហានមានពីរស្ថាន គឺសេចក្ដីក្លាហានព្រងើយកន្ដើយម្យ៉ាង, សេចក្ដីក្លាហានសកម្មម្យ៉ាង ។

១-សេចក្ដីក្លាហានព្រងើយកន្ដើយ គឺជាសេចក្ដីទ្រាំទ្រចំពោះការឈឺចាប់ ហើយនឹងមិនខ្លាចសេចក្ដីស្លាប់ ។ បើខ្ញុំមានជម្ងឺយ៉ាងធ្ងន់ ត្រូវដេកនៅនឹងមួយកន្លែងជាយូរអង្វែង ដោយឥតត្អូញត្អែរពីការឈឺចាប់របស់ខ្ញុំ; នោះគេសន្មតថា ខ្ញុំមានសេចក្ដីក្លាហានព្រងើយកន្ដើយ ។ សេចក្ដីក្លាហានព្រងើយកន្ដើយជាន់ខ្ពស់ហៅថា ឧបេក្ខា (résignation), កាលបើខ្ញុំមានក្រុមញាតិទទួលមរណភាព, នៅពេលនោះខ្ញុំមានទុក្ខធ្ងន់ឥតឧបមា ។ ក៏សេចក្ដីទុក្ខនោះ ដែលស្ទប់ រ[illegible]ប់នៅក្នុងចិត្តរបស់ខ្ញុំបាន មកពីខ្ញុំខំកាត់ចិត្តឲ្យទុក្ខនោះបានស្រាល ដើម្បីបំពេញករណីយកិច្ចឯទៀតរបស់ខ្ញុំ ។ ការខំកាត់ចិត្តនោះ គឺការខំធ្វើចិត្តឲ្យនៅជាកណ្ដាល ៗ កុំឲ្យទុក្ខធ្ងន់ពេក ហៅថា ឧបេក្ខា ។

២– សេចក្តីក្លាហានសកម្ម គឺការតុះតារឲ្យឈ្នះសេចក្តីខ្លាចខ្លួនឯង ដូចជាសេចក្តីក្លាហានរបស់ពលរដ្ឋ ដែលចូលច្បាំងក្នុងពេលដែលមានគ្រាប់កាំភ្លើងបាញ់មកត្រង់ដូចជាទឹកភ្លៀង នឹងសេចក្តីក្លាហានរបស់គ្រូពេទ្យដែលទៅមើលមនុស្សមានជម្ងឺធ្ងន់ ដូចជាជម្ងឺអាសន្នរោគនឹងជម្ងឺពិសជាដើម មិនខ្លាចឆ្លងមកដល់ខ្លួនធ្វើឲ្យមានគ្រោះថ្នាក់ដល់ស្លាប់ដូច្នោះឯង ។

សេចក្តីក្លាហានខាងផ្លូវចិត្ត គឺសេចក្តីក្លាហានអាចតយុទ្ធនឹងដំនឿខុស ហើយអាចឲ្យមានសេចក្តីគោរពដល់មនុស្ស ។ បើនៅក្នុងគ្រួសាររបស់ខ្ញុំ, គេតែងយល់ថាគ្រួសារនេះមានតម្លៃជាងគ្រួសារដទៃ ហើយខ្ញុំយល់អ្នកឯង ថាជាមនុស្សមានតម្លៃស្មើ ៗ គ្នា ។ ខ្ញុំចូលទៅប្រាស្រ័យនឹងអ្នកដទៃដោយឥតឆ្មើងឆ្មៃ នោះត្រូវថាខ្ញុំមានសេចក្តីក្លាហានខាងផ្លូវចិត្ត ។ សេចក្តីក្លាហានខាងផ្លូវចិត្ត ជាសេចក្តីក្លាហានសម្រាប់តយុទ្ធនឹងខ្លួនឯង ។

សេចក្តីក្លាហានមិនមានតម្លៃដោយឯកឯងទេ គឺអាស្រ័យនឹងគោលបំណង ដែលសេចក្តីក្លាហាននោះអាចឲ្យសម្រេចបាន ។ បើ

គោលបំណងល្អ ទើបសេចក្ដីក្លាហានមានតម្លៃ; បើគោលបំណងអាក្រក់, សេចក្ដីក្លាហាននោះក៏ឥតអំពើ ។ ពលដែលចូលទៅប្រយុទ្ធដើម្បីជួយមាតុភូមិក្នុងពេលមានអាសន្ន គេត្រូវទុកថាពលនេះមានសេចក្ដីក្លាហានដ៏ប្រសើរ, ប៉ុន្តែ បើខ្ញុំមានសេចក្ដីក្លាហានយកក្រមាទៅចងកឲ្យស្លាប់វិញ, នោះគ្មាននរណាគេសរសើរថាខ្ញុំមានសេចក្ដីក្លាហានទេ, មានតែពាក្យបន្ទោសថា ខ្ញុំចង់បំបាត់សេចក្ដីទុក្ខវេទនាក្នុងបច្ចុប្បន្នកាល ដើម្បីចៀសវាងឲ្យផុតពីករណីយកិច្ចក្នុងអនាគតកាល ។

ចោទសួរ- ដូចម្ដេចហៅថាសេចក្ដីក្លាហាន? មានប៉ុន្មានយ៉ាង? សិស្សត្រូវក្លាហានក្នុងការរៀនសូត្រដែរឬ? ទាហានត្រូវមានអ្វីជាគុណសម្បត្តិរបស់ខ្លួន?

## វិធីអាន

## សុធនកុមារជាគំរូក្នុងការក្លាហាន

គ្មានអ្វីនឹងរារាំងនូវបុគ្គលដែលមានឆន្ទៈដ៏មោះមុត ព្រោះបំណងជាហេតុនាំបុគ្គលឲ្យឆ្លងនូវឧបសគ្គទាំងឡាយបាន ។

សុធន ជាកុមារម្នាក់មានកំណើតកើតជានៅឃុំសន្ទុង ស្រុក

វិហារសួគ៌ ជាកូនជាងថ្នាក់មានកេរ្តិ៍ឈ្មោះ នៅក្នុងភូមិនេះ ។ វង្សត្រកូលល្អរបស់វា ក៏បានយកវាឲ្យទៅរៀនសូត្រឯវត្ត បានចេះដឹងគ្រាន់បើ ។ វាទើបនឹងបានអាយុ ១៤ ឆ្នាំ, ក៏ឪពុកវាធ្លាក់ទៅជាអ្នកទល់ក្រ ហើយរត់ទៅលាក់ខ្លួនពួនអាត្មាឯស្រុកកញ្ជ្រៀច ខេត្តព្រៃវែង នាំទាំងកូនចៅទៅផង, ដោយសេចក្ដីព្រួយលំបាកពេក មិនយូរប៉ុន្មានក៏ទទួលមរណភាពទៅ ។ ម្ដាយវាក៏ចូលទៅថ្វាយខ្លួនជាយាយជីវត្ត ។ កុមារសុធននៅតែម្នាក់ឯងជាមួយនឹងប្អូនប្រុសជំទង់, គិតសព្វគ្រប់ទៅ ក៏កាន់ដៃប្អូនយាត្រាត្រឡប់មកស្រុកដើមរបស់ខ្លួនវិញ ។ ក្នុងខណៈនោះ វាមានប្រាក់តែ ២រ៛៤០ គត់ ឥតមានធនធានអ្វីក្រៅពីនេះទេ កំសត់ពេក តែពីរនាក់នឹងបងប្អូន នាំគ្នាដើរលេចព្រៃចូលវាល, ដល់មកវាលមួយ ទទួលប្រទះនឹងរទេះឈ្នួលមួយ ក៏និយាយសុំគេឲ្យប្អូនជិះ, បានដោះអាវខ្លួនឲ្យទៅប្អូនពាក់ ដោយពេលនោះជារដូវរងា ។ ចំណែកខាងវាក៏ដើរតាមរទេះនោះមក ។ យូរៗម្ដងៗអ្នកម្ចាស់រទេះ ក៏បានឲ្យកុមារសុធន ដែលជាមេបាតូចក្នុងគ្រួសារ ឡើងជិះខាងមុខត្រង់អ្នកបរ;

រំលងបីថ្ងៃទើបបានដល់ភូមិដើមរបស់ខ្លួន ។ ដល់មកស្រុកកាលណា ក៏ម្នាចាប់ការងារខាងជាងឆ្លាក់ដំណែលរបស់ឪពុក, បានប្រមូលថ្មយកមកឆ្លាក់ ខំធ្វើការទាំងយប់ទាំងថ្ងៃ លក់បានប្រាក់កាសទៅជាអ្នកមានធនធានគ្រាន់បើនឹងគេ ។ អ្នកស្រុកទុកភូមិក៏មានសេចក្ដីអាណិតអាសូរសរសើរ ចំពោះសេចក្ដីជំនះព្យាយាមរបស់កក្កងការគេស៊ី ។ កបានចិញ្ចឹមប្អូននឹងម្ដាយរៀងរាបមក ហើយសម្ដីព្យាយាមរៀនសូត្រទៅ ។

## ពន្យល់ពាក្យ

**ជាងឆ្លាក់** ន. ជាងឆ្លាក់ថ្ម ឬឈើ ធ្វើជារូប ឬក្បាច់ផ្សេង ៗ ។

**វង្សត្រកូលល្អ** ន. គុ. គ្រួសារដែលអ្នកផងរាប់អាន ។

**មរណភាព** ន. សេចក្ដីស្លាប់ ។

**លេចព្រៃចូលភូមិ** កិ. ចេញពីព្រៃចូលទៅក្នុងភូមិ ។

* * * *

## មេរៀនទី ២៤ សេចក្ដីខ្នះខ្នែង, ព្យាយាម

## **Energie et persévérance**

១ – សេចក្ដីខ្នះខ្នែង គឺជាកិរិយាអង់អាច មិនទំរេទចំពោះការអ្វីមួយ ៗ លុះតែគេមានសេចក្ដីអង់អាច ទើបធ្វើការទាំងពួងបានសម្រេច ។

អធិប្បាយថា: សិក្ខាកាមកុលបុត្រដែលចូលចិត្តធ្វើការរៀនសូត្រ បើទុកណាជាមានការលេងសប្បាយទាំងឡាយក៏ដោយ ក៏ត្រូវតែមានសេចក្ដីខ្នះខ្នែងជាមេ ៗ ដូចយ៉ាងការធ្វើចំណោទ ឬតែងសេចក្ដីណាដែលលំបាក ក៏ត្រូវប្រើសេចក្ដីខ្នះខ្នែងអង់អាចនេះជាប្រមុខទើបអាចសម្រេចបាន ។ សេចក្ដីខ្នះខ្នែងជាប្រមុខពួកកម្មករ (ouvrier) ដែលចូលទៅកាន់រោងជាង ឬទៅស្រែចម្ការ ដើម្បីរកចិញ្ចឹមជីវិត ។ សេចក្ដីខ្នះខ្នែងជាប្រមុខរបស់អ្នកប្រាជ្ញ ដែលត្រូវការស្វែងរកសម្ងាត់ពីធម្មជាតិ; ជាប្រមុខរបស់អ្នកត្រាច់ស្វែងរកកន្លែងដែលមានគ្រោះថ្នាក់ ក្នុងការដែលចិញ្ចឹមជីវិតរបស់ខ្លួន ។

២ – សេចក្ដីព្យាយាមនិងសេចក្ដីអង់អាចជាគូនឹងគ្នា ជាកិច្ច

ទ្រុមនោះបានហើយក៏ចេញមក មានសេចក្ដីខឹងនឹងទន្សាយនោះមហិមា នឹងទៅតាមចាប់វា ពេលក៏ស្រទន់ជិតល្ងាចហើយ, មេខ្លាក៏វិលត្រឡប់ទៅកាន់សំបុកកូនខ្លួនវិញ ដល់ហើយកូនទាំងពីរក៏សួរថា ម៉េចទៅម៉ែ! តាទន្សាយនោះម៉ែបានពិឃាតវាហើយឬ? មេខ្លាប្រាប់ថា "ពិឃាតវាឯណាបាន ម៉ែទៅនេះប៉ុនគេយកគេគ្តិខ្ទាសទៅឲ្យវាជាម្ដង, ណ្ហើយចុះ ថ្ងៃនេះឯងធ្វើការបរាជ័យចាញ់វា ចាំថ្ងៃក្រោយៗទៀតសឹមកែខ្លួនឲ្យបាន" ថាហើយមេខ្លាក៏ចូលទៅបំបៅកូនក្នុងរូងនោះហោង ។

## ការអាន

## ការក្រោធនាំឲ្យខាត

មានពពែពីរតួ ដើរមកទល់ជួបគ្នានៅកណ្ដាលស្ពាន ។ ពពែ១ថា ស្ពាននេះដើរបានចំពោះតែតួមួយ ៗ នឹងដើរជៀសគ្នាពុំបាន, បើដូច្នេះត្រូវតែអ្នកឯងថយទៅក្រោយសិន ចាំយើងដើរទៅដល់ចុងស្ពានកាលណា សឹមអ្នកឯងដើរមកចុះ ។ ពពែ១ទៀតថា យើងឯងមានការជាបន្ទាន់ ត្រូវតែអ្នកឯងថយទៅខាងក្រោយសិន ចាំយើង

ដើរទៅដល់ចុងស្ពានកាលណា សិមអ្នកឯងដើរទៅចុះ ៗ ពពែទាំងពីរសើចពុំព្រមថយក្រោយដូចគ្នា កាន់មានះរៀងខ្លួន ក៏បោលសំរុកដល់គ្នារុញទៅរុញមក ដោយកំឡាំងតោសោមោះហោ ប៉ាំងប៉ង ឥតប្រាជ្ញាទីងសម្របគ្នា ៗ ដល់គ្នាធ្លាក់អំពីលើស្ពានទៅក្នុងទឹក ទាំងពីរតួ បានក្តីវេទនាដោយធ្លាក់ទឹកមានអាការៈផ្សេង ៗ ៗ

រឿងនេះបានគតិដូចបុគ្គលដែលវិវាទគ្នា ដណ្តើមឈ្នះរៀងខ្លួន ចុះក្នុងក្បួនបុរាណថា "ខឹងកើតខាត់, មានដំកាត់ឈើគោត, មានក្តីក្រោធក្រោយក្រៀមមុខ, ខំសំរុកធ្លាក់ទឹក" ដូចនិទានពពែទាំងពីរនេះឯង គួរចូលចិត្តចុះ ៗ

## ការអាន

មានសត្វរាជសីហ៍ ១ ចុះទៅផឹកទឹកស្រះ ៗ កាលនោះមានសត្វក្អែប ១ នៅក្នុងស្រះ បានឃើញរាជសីហ៍ចុះមកផឹកទឹកដូច្នោះ ក៏ស្រែកកំហែងទៅថា រឺយរាជសីហ៍ ហេតុអ្វីចៅមកលួចផឹកទឹកយើង, ចៅសុំនរណាហ: ស្រះនេះជាស្រះរបស់យើង គួរតែគំនាប់យើងជាម្ចាស់ស្រះខ្លះអេះ, នេះឯងព្រហើនកោងមកផឹកទឹកមិនសុំ

យើងជាម្ចាស់ទៀយ ៗ ឯរាជសីហ៍ឮកង្កែបពោលមកដូច្នោះ ក៏ពោ-សោខ្លាំង ទើបតបវិញថា រឺយអាកង្កែបតូចប្រមក់! ស្រះនេះម៉ែអាឯងវែកមកឬ ទើបបានអាឯងមកពោលថាខ្លួនជាម្ចាស់ស្រះ, ស្រះនេះហៅជាតស្រះ គឺស្រះកើតឯងតាំងពីព្រេងមក ជាស្រះសម្រាប់ពួកសត្វចតុប្បាទទ្វេបាទទឹងមនុស្សទាំងឡាយ គេតែងអាស្រ័យ, នេះហេតុអ្វីអាឯងមកកំហែងអញ ថាអញមិនគំនាប់សុំអាឯងនោះ, អញចាំបាច់សុំពានអាឯងធ្វើអ្វី, អាឯងជាម្ចាស់ពីកាលណា, នែអាកង្កែបអែបនាគុម្ពផ្កា, អាមិនស្គាល់ឫទ្ធិបេស្ដាអញជាស្ដេចលើក្បាលអាឯងទេឬ? កង្កែបតបថា រឺយរាជសីហ៍! ឯងអួតថាខ្លួនជាស្ដេចៗមែនហើយ, តែជាស្ដេចលើសត្វចតុប្បាទខាងជើងគោក; ឯអញនេះសោតក៏ជាស្ដេចលើសត្វខាងជើងទឹក, ឫទ្ធិបេស្ដាអាឯង ក៏មិនលើសលែងគ្នា; អញក៏ពុំកោតក្រែងឫទ្ធិអំណាចអាឯងប៉ុន្មានឬអាឯងស្រែកសម្រែកឲ្យសត្វទាំងឡាយរាធោត នាំគ្នាកោតខ្លាចសម្រែករាជសីហ៍ទូទៅ, ត្រង់រូបអញ ១ នេះមិនធោត មិនទៅកោតខ្លាចសម្រែកអានោះទេ, អាចង់ស្រែកយ៉ាងណា ក៏អញមិនព្រឹម ៗ ឯរាជសីហ៍បានឮកង្កែប

ពោលពាក្យឥតក្រែងដូច្នេះ ក៏គិតថា "អញនឹងបញ្ចេញនូវសម្រែក ឲ្យសត្វកន្ធែបនេះស្លាប់ក្នុងកាលឥឡូវនេះឯង" គិតហើយរាជសីហ៍ ក៏ស្រែកដោយឫទ្ធិយ៉ាងខ្លាំងឡើង ៗ ឯកន្ធែប, កាលរាជសីហ៍នោះ ស្រែក, ក៏លោតចាកស្លឹកឈើកមុជចុះទៅក្នុងទឹក, លុះសម្រែក រាជសីហ៍ស្ងប់បាត់ហើយ, វាក៏ងើបឡើងទំលើស្លឹកឈើកវិញ ហើយ ពោលឡកទៅថា ឱ្យរាជសីហ៍! ឯងស្រែកអម្បាញ់មិញនេះពុំមិន ស្មើនឹងដោមផង ចូរឯងស្រែកម្ដងទៀតទៅមើល ៗ

ឯរាជសីហ៍ពោសោខ្លាំង ក៏តាំងស្រែកឡើងលើសមុន ដើម្បីឲ្យ កន្ធែបស្លាប់ ៗ ឯកន្ធែបក៏មុជចុះទៅក្នុងទឹកទៀត, លុះស្ងប់សព្ទរាជ សីហ៍កាលណា, វាក៏ងើបឡើង ទំលើស្លឹកឈើកហើយវាឡកបំអកឲ្យ រាជសីហ៍ដោយប្រការផ្សេង ៗ ៗ ឯរាជសីហ៍ក៏រឹតតែខឹងខ្លាំងតាំង ប្រឹងស្រែកខ្លាំងឡើង ៗ ពល់តែប្រេះបែកបំពង់ក ដួលចុះដល់នូវ ក្ដីមរណកាលក្នុងកាលនោះហោង ៗ កន្ធែបឃើញរាជសីហ៍ស្លាប់ ដូច្នោះ ក៏ត្រេកអរដោយសមសេចក្ដីប្រាថ្នារបស់ខ្លួន ៗ

រឿងនេះបានគតិដល់បុគ្គលពោសោ ក្រោធខឹងមិនគិត អាង

ឥទ្ធិរិទ្ធិ សតិប្រាជ្ញា មិនពិចារណាឲ្យយល់ហេតុ ទីដ៏អន្តរាយខ្លួន ទៅខាងមុខ គិតតែថាខ្លួនឯងធំ ឯងមានអំណាច កើតសេចក្ដីមើលងាយអ្នកតូច វិនាសខ្លួនដូចសត្វរាជសីហ៍នោះហោង ។

* * * *

## មេរៀនទី ២៦ ការមានលក្ខណៈជាការចាំបាច់

### Nécessité d'avoir du caractère

១– ដម្បីមួយយ៉ាងរបស់ប្រទេសកម្ពុជាយើងសព្វថ្ងៃ ដែលត្រូវឲ្យរងទុក្ខលំបាក គឺប្រទេសយើងនៅខ្វះមនុស្សប្រុស-ស្រីដែលមានលក្ខណៈ គឺមិនបរិបូណ៌ដោយលក្ខណៈល្អ មិនមានឆន្ទៈដោយមុឺងម៉ាត់ ។

អធិប្បាយថា: បុគ្គលដែលមានលក្ខណៈ គឺបុគ្គលដែលបរិបូណ៌លក្ខណៈល្អ ចេះធ្វើខ្លួនឲ្យថ្លៃថ្នូរ ស្គាល់ករណីយកិច្ចរបស់ខ្លួនហើយខំបំពេញដោយម៉ត់ចត់ ។ បើគេមានវិចារណញ្ញាណល្អមានចិន្តាចំ-ពោះការអ្វីមួយ គេមិនគិតគូពីការរបស់អ្នកដទៃឡើយ, មិនចេះតែចាំស្ដាប់បង្គាប់ពីមនុស្សមួយទៅមនុស្សមួយនោះទេ, គេមានគោល

បំណងសំខាន់ៗ របស់គេ ហើយគេសម្រេចកិច្ចនោះតាមគេយល់ឃើញ ។ ដូច្នេះគេនឹងបានទទួលសេចក្ដីរាប់អានពីមនុស្សទាំងឡាយ ព្រមទាំងជាមនុស្សមានវុឌ្ឍិអំណាចដ៏ថ្លៃថ្នូរ ។

២– បុគ្គលអ្នកមានលក្ខណៈ គេអាចនឹងសម្រេចកិច្ចការទៅតាមកាលៈទេសៈដែលលំបាក គេមិននៅនឹងថ្កល់ចំពោះការដែលមិនសម្រេចនោះទេ ។

អធិប្បាយថាៈ មនុស្សប្រកបដោយលក្ខណៈ តែងគិត តែងថ្លឹងការនោះៗ ហើយគេសម្រេចយកខាងការណាល្អ រួចគេដើរទៅមុខឥតគិតពីការស្ទាក់ស្ទើរនោះឡើយ, គេប្រឹងជំនះក្នុងការលំបាក ។ ដូច្នេះគេនឹងបានសម្រេចកិច្ចការនោះដោយសេរី បានឈ្មោះថាជាកិត្តិយស ១ ដ៏ប្រសើរ ។

៣– កុំឲ្យប្រឡំការមុឺងម៉ាត់របស់លក្ខណៈ ថាដូចជាការដែលធ្វើយ៉ាងរហ័សក្ដាមៗ (តូងតាងដេកថ្ងូរ) នឹងការរឹងរូស (ក្បាលរឹង) ដែលជាលក្ខណៈវិបត្តិនោះឡើយ ។

អធិប្បាយថាៈ ការរហ័សក្ដាមៗ គឺជាការដែលធ្វើដោយឥត

គិតគូឲ្យម៉ត់ចត់ជាមុន, ម្ល៉ោះហើយដល់ធ្វើទៅតែងតែជួបប្រទះនឹងឧបសគ្គ ហើយតែងតែកាមកក្រោយវិញ ។ មនុស្សក្បាលរឹង គឺមនុស្សធ្វើការអ្វី ៗ ច្រើនធ្វើដំនះតែនឹងចិត្តឯង មិនព្រមទទួលថាខ្លួនធ្វើខុសនាំឲ្យមានគ្រោះថ្នាក់សោះ ។

៤– យើងមិនត្រូវធ្វើខ្លួនឲ្យទៅជាមនុស្សស្អាក់ស្អើរ, ត្រូវឲ្យទៅជាមនុស្សមានធ្នុះម៉ឺងម៉ាត់, មិនជាមនុស្សរួញរា ឲ្យជាមនុស្សរឹងប៉ឹង មិនធ្វើឲ្យទៅជាមនុស្សទន់ប៉ផ្ដៀប ដូចជាក្រមួនត្រូវថ្ងៃនោះទេ ពុំនោះសោត ឲ្យដូចជាកង្ហារដែលចេះតែវិលទៅតាមខ្យល់នោះឡើយ ។ ហេតុនេះយើងត្រូវទម្លាប់ធ្វើការអ្វី ៗ ឲ្យម៉ឺងម៉ាត់ម៉ត់ចត់, ដ្បិតថាមនុស្សយើង បើខ្វះគុណសម្បត្តិអស់ទាំងនេះហើយ មិនមែនជាមនុស្សទេ ត្រឡប់ទៅជាសត្វឬវត្ថុទៅវិញ ។

(សូមឲ្យគ្រូលើកឧទាហរណ៍ យកក្មេងរូបណាមួយដែលមានសេចក្ដីឈឺចាប់ហើយមិនចេះត្អូញត្អែរ ទាំងមិនស្រក់ទឹកភ្នែក ជាក្មេងចេះអត់ធន់ដូចជាមនុស្សចាស់, យកកសិករ (អ្នកស្រែ-ចម្ការ) ដែលស៊ូទ្រាំធ្វើការចិញ្ចឹមជីវិតហាលថ្ងៃភ្លៀងខ្យល់ញើសតានទឹក

ឥតមានញញួរ, យកស្នែងសត្វស្មោញដែលស៊ីព្រាំមុខចំករកអាហារ, យកឆ្អឹងចម្បាំងដែលស៊ីព្រៃរងគ្រាប់រំសេវ មិនមានញញួរគក់ស្លុត តាំងនេះមកពន្យល់សិស្សឲ្យជាគំរូក្នុងរឿងនេះ) ។

ចោទសួរ– នៅប្រទេសកម្ពុជា សម្បូណ៌ដោយមនុស្សមានលក្ខណៈឬទេ? ហេតុដូចម្ដេចក៏មនុស្សត្រូវឲ្យមានលក្ខណៈ? មនុស្សដែលមានលក្ខណៈសម្រេចកិច្ចការបានយ៉ាងណា? ការរហ័សភ្លាមៗ ដែលហៅថាខ្លួនតាងដើកផ្លូវនោះដូចម្ដេច? មនុស្សរឹងរូសដែលហៅថាក្បាលរឹងដូចម្ដេច? សេចក្ដីយល់ឃើញរបស់អ្នកចំពោះលក្ខណៈទាំងនេះដូចម្ដេច?

## ការអាន

បុគ្គលប្រាថ្នាលាភលើសកាលកំណត់ មិនសង្ឃឹមទៅតាមកាល លោភចង់បានឲ្យច្រើនតែម្ដង លាភនោះនឹងខាតទៅព្រមនោះ ព្រោះមិនបានគិតវែង ដោយធ្វើភ្លាមៗឥតគិតពិចារណា ។

បុរសម្នាក់ ចិញ្ចឹមមេមាន់ដើម្បីយកពងលក់ ។ មេមាន់នោះ លុះដល់កំណត់ពង ក៏ពងក្នុង១ថ្ងៃមួយ ៗ រៀងទៅតាមធម្មតា ។

ឯចៅម្ចាស់មាន់បង់បានច្រើនតែម្ដង ក៏ចាប់មេមាន់នោះរឹតយកពងឲ្យអស់តែម្ដង ។ ឯពងខ្ចីពងចាស់ទាំងឡាយក៏បែកល្អិតខ្ទេចខ្ទីដោយដៃចៅនោះរឹតច្របាច់ខ្លាំង ទាំងមេមាន់សោត ធន់នៅពុំបាន ក៏ស្លាប់បង់ក្នុងកាលនោះ ។ ចៅម្ចាស់ក៏បង់លាភនៅត្រឹមនោះឯង ។ សមដូចភាសិតថា "ចចើនចង់លាភ វង់បាត់ធនចៅ" ។

## មេសូត្រ

រៀនសិល្បកុំពន់បន្ទាន់ញាប់ ស្វែងទ្រព្យសន្សំកុំខំខ្លាំង ឡើងក្ដីសន្សឹមកុំប្រណាំង សេពកាមតាមកំលាំងតិចៗក៏ ។ ខឹងហោរតិចៗកុំឲ្យស៊ិន កាមគុណទាំង៥ជាមាត្រា សន្សឹមតិចៗ មើលកិរិយាលោកថាសន្សឹមកុំបំពោល ។

## ពន្យល់ពាក្យ

មេមាន់ ន. សត្វស្លាបទ្វេបាទ គេចិញ្ចឹមទុកបរិភោគ ។

រឹតយកពង កិ. ន. ច្របាច់យកពង ។

សន្សឹមកុំបំពោល កិ. ពាក្យបុរាណទូន្មានឲ្យធ្វើការអ្វីសន្សឹមៗ កុំ

ប្រញាប់ទៅតាមក្តីចង់ពេក ៗ

# ការអាន

## មនុស្សលោភច្រើនខាតដើមទៅវិញ

មានទាហ៊ាន២នាក់ ម្នាក់ជាទីឧកញ៉ាយោមរាជ ម្នាក់ទៀតជាទីឧកញ៉ាពលទេព ៗ ឯឧកញ៉ាពលទេព ជាមនុស្សលោភបុណ្យស័ក្តិ ចង់បានទីយោមរាជ កើតស្អប់ឧកញ៉ាយោមរាជ គិតស្វែងរកទោសដាក់ នឹងក្រាបទូលព្រះរាជាសុំទំលាក់ចោលទីយោមរាជ ដើម្បីអាត្មាឯងនឹងបានស្តីទីយោមរាជនោះតទៅ ៗ ឧកញ៉ាពលទេពស្វែងរកទោសលោកយោមរាជនោះជាយូរខែមកហើយ ៗ ថ្ងៃមួយមានអ្នកទោសម្នាក់មានទោសធ្ងន់ ក្រុមជំនុំកាត់ទោសដល់ប្រហារជីវិតៗឯអ្នកទោសនោះដឹងថាថ្ងៃព្រឹកស្អែកនេះហើយ គេនឹងនាំអាត្មាទៅសម្លាប់ជាប្រាកដ គិតសោកវិយោគស្តាយជីវិតមហិមា យំពណ៌នាថា ឱជីវិតអញអើយ! ព្រឹកស្អែកនេះហើយនឹងបង់ចាកប្រាណ, អើត្រង់ក្តីស្លាប់១នេះនរណាឡើយនឹងវៀរបង់បាន តែកើតឡើងហើយរមែងតែងស្លាប់ជាធម្មតា តែជាត្រង់ជីវិត១នេះទោះបង់បាត់ទៅក្តី ក៏មិនសូវជាសោក

ស្តាយអ្វីប៉ុន្មាន មកសោកស្តាយតែវិជ្ជា ១ ដែលខ្លួនបានបេះហើយពុំ
ពាន់បានបង្ហាត់បង្ហាញនរណា ១ សោះ, បើព្រឹកនេះខ្លួនស្លាប់ហើយ,
វិជ្ជានេះយល់ជានឹងសូន្យសោះ អស់មាននរណាមួយក្នុងលោកនេះ
ការបេះតទៅបានឡើយ ។

កាលនោះ មាននាយគូឃុំម្នាក់ បានឮចៅនោះយំពណ៌នា សោកស្តាយវិជ្ជាដូច្នោះ ក៏ចូលទៅសាកសួរថា ចៅឯងព្រឹកនេះដល់ក្តីស្លាប់ប្រាកដហើយ ចៅយំរៀបរាប់ថា គ្រាន់ជីវិតរូបកាយមិនសូវស្តាយប៉ុន្មាន មកស្តាយតែវិជ្ជាមួយដែលបេះមក តើវិជ្ជានោះឈ្មោះវិជ្ជាអ្វី ចូរប្រាប់យើងមើល ។

ឯអ្នកទោសក៏ប្រាប់ថា ខ្ញុំបាទបេះវិជ្ជាជីងកាសាសត្វ; វិជ្ជានេះវិសេសរបស់ខ្ញុំបាទណាស់ ក្នុងលោកនេះគ្មាននរណាបេះសោះ, តែខ្ញុំបាទដល់ក្តីស្លាប់ហើយ, វិជ្ជានោះសូន្យជាម្តង ព្រោះពុំមាននរណាបានមករៀនតទៅឡើយ ។ នាយគូឃុំឮដូច្នេះហើយ ក៏នាំសេចក្តីនុ៎ះទៅជំរាបលោកឧកញ៉ាយោមរាជ សព្វប្រការ ។ ឯឧកញ៉ាយោមរាជ ក៏នឹកក្នុងចិត្តថា “វិជ្ជានោះវិសេសក្រៃពេកណាស់ គួរតែរៀន

យក" ទើបនាំនាយឃុំ ទៅដោះអ្នកទោសចាកគ្រឿងចាំ ហើយសួរបញ្ជាក់ជាពិតឬពុំពិត ៗ ឯអ្នកទោសក៏ជំរាបថាបេះពិតប្រាកដមែន ៗល ៗ លោកក៏បានដោះលែងអ្នកទោសនេះទៅ ៗ រឿងលែងមនុស្សទោសក៏មិនបាត់ស្ងាត់ ។ ថ្ងៃមួយព្រះរាជាទ្រង់ចេញមកដាក់បាត្រព្រះសង្ឃ ក៏ឮសួរហ្វូងក្អែកស្រែកកញ្ជ្រៀវ ក៏ទ្រង់សួរទៅឧក-ញ៉ាពលទេពពីហេតុដែលក្អែកកញ្ជ្រៀវ ៗ ឧកញ៉ាពលទេពដែលបំ-រុងរករឿងឧកញ៉ាយោមរាជស្រាប់ ក៏បានឱកាសទីនទូលព្រះរាជាថាឧកញ៉ាយោមរាជទើបបានចេះភាសាសត្វ ៗ ព្រះរាជាក៏ឲ្យហៅឧកញ៉ាយោមរាជមកសាកសួរ ៗ ឧកញ៉ាយោមរាជក៏បានឆ្លើយថាចេះមែន ៗ ព្រះរាជាក៏ឲ្យឧកញ៉ាយោមរាជស្ដាប់សំឡេងសត្វក្អែកដែលកំពុងស្រែកកញ្ជ្រៀវ ៗ ឧកញ៉ាយោមរាជ ក៏ធ្វើជាផ្ទៀងត្រចៀកស្ដាប់សត្វក្អែកខាងម្ខាង ហើយបែរទៅស្ដាប់សត្វក្អែកខាងម្ខាងទៀតហើយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស, ហ្វូងក្អែកដែលទំលើដើមឈើនោះ ជាហ្វូងក្អែកស្រុកក្រៅ, ឯហ្វូងក្អែកដែលទំលើដំបូលប្រាសាទនោះ ជាហ្វូងក្អែកនៅក្នុងក្រុងនេះ ៗ ព្រះរាជា

ពុទ្ធនោះ ក៏ត្រាស់សួរទៅវិញថា ចុះក្អែកស្រុកក្រៅពីយកគង់ តើយំថាដូចម្ដេច? ក្អែកក្នុងក្រុងតើស្រែកថាដូចម្ដេច ? ឧកញ៉ាយោមរាជក្រាបទូលថា ក្អែកស្រុកក្រៅមានក្ដីក្ដៅក្រហាយ ដោយអ្នកស្រុកមិនបានធ្វើបុណ្យឲ្យបានដូចឆ្នាំមុនៗ, ដ្បិតពីឆ្នាំមុនៗ អាណាប្រជានុរាស្ត្រសម្បូណ៌ស្រូវអង្ករនាំគ្នាធ្វើបុណ្យនិមន្តលោកសង្ឃឆាន់; ឯចំណីអាហារដែលសេសសល់នោះគេបោះឲ្យបានដល់សត្វក្អែកប្រសត្វឯទៀតផង; សត្វក្អែកសឹងបានបរិភោគចំណីនោះទូទៅ; សេចក្ដីសុខសប្បាយក៏មានគ្រប់ដម្បូន; ឥឡូវនេះឧកញ៉ាពលទេពជានាយក្សេត្រចាត់មកគង់អាជ្ញាលួង ចេញទៅកត់ពន្ធស្រូវៈធ្វើមិនត្រូវតាមប្រវេណី, គេយកពន្ធពីរាស្ត្រលើសប្រមាណ រាស្ត្រគ្នាតវ៉ាក៏មិនបាន ស្រូវបួនប្រាំថាំងក៏ឲ្យជាប់ពន្ធដែរ, មួយទៀតស្រូវគ្នាហាហុកសិប បង្កើនដាក់ទៅដល់កៅសិបមួយរយ, យកបុណ្យសក្ដិបង្ក្រិបគ្នា ដោយអំពើផ្សេងៗ; ពួកប្រជារាស្ត្រកើតក្ដីក្រលំបាកក្ដៅក្រហាយជាពល់ៗ គ្នា បានជាឆ្នាំនេះ មិនមាននរណាអាចធ្វើបុណ្យបាន; ពួកក្អែកទាំងឡាយ ពុំបានទទួលទានភោជនាហារ ដែលសេសសល់នោះឯង

ទើបវានាំគ្នាចូលមកក្នុងក្រុង ដើម្បីថ្លែងសេចក្ដីលំបាករបស់រាស្ត្រ ដល់ពួកក្អែកជាញាតិនៅក្នុងក្រុង នាំសេចក្ដីក្ដៅក្រហាយ ឡើងក្រាបបង្គំទូលព្រះករុណាជាម្ចាស់ផែនដី ឲ្យសូមទ្រង់ជ្រាបពីការឧកញ៉ាពលទេពប្រព្រឹត្តខុសព្រះរាជបញ្ញត្តិ សូមល្អងធូលីព្រះបាទស្ដេចទ្រង់ជ្រាប ។

ឯព្រះបរមរាជា បានទ្រង់ព្រះសណ្ដាប់ពាក្យឧកញ៉ាយោមរាជដូច្នេះ ក៏ត្រូវព្រះទ័យ ទើបទ្រង់ទ្រាល់ទឹងឧកញ៉ាពលទេព ដែលគោងនរាស្ត្រធ្វើឲ្យរាស្ត្រក្ដៅក្រហាយ ពេញទាំងព្រះរាជអាណាខេត្ត, ស្ដេចទ្រង់ឲ្យដកងារឧកញ៉ាពលទេពចេញចាកមន្ត្រី ប្រោសប្រទានឧកញ៉ាយោមរាជឲ្យឡើងទីជាសម្ដេចចៅហ្វាឧត្ដមមហាសេនា ស្ដីរាជការទៅក្រសួងអធិបតី ។

## ពន្យល់ពាក្យ

ឧកញ៉ាយោមរាជ ន. សេនាបតីកាន់ការក្រសួងយុត្តិធម៌ វិនិច្ឆ័យក្ដីដោយយុត្តិធម៌ ។

ឧកញ៉ាពលទេព ន. មន្ត្រីកាន់ការខាងពន្ធដារផ្សេងៗ ។

នាយភូឃុំ ន. អ្នកត្រួតត្រារក្សាមនុស្សទោស ។

ខ្ញាល់ កិ. ខឹង, ស្តេចខ្ញាល់, លោកសង្ឃខ្ញាល់ ។

* * * *

មេរៀនទី ២៧

## បរិសុទ្ធិ

### La pureté.

១ សេចក្តីបរិសុទ្ធិ ជាគុណសម្បត្តិមួយយ៉ាងល្អ ដែលមិនឲ្យមានមន្ទិលសៅហ្មងដល់ខ្លួនទាំងចិត្ត ។

អធិប្បាយថា: សេចក្តីបរិសុទ្ធិ ក៏ដូចជាការមុតធន់ទាំងសេចក្តីព្យាយាមយ៉ាងអ៊ឹងម៉ាត់របស់ចិត្ត ដែលជាបន្ទាត់របស់ខ្លួន មិនឲ្យមានមន្ទិលកខ្វក់ចូលមកល្អុកល្អុយបាន ។ ចិត្តបរិសុទ្ធ គឺជាចិត្តស្អាតល្អ ជាចិត្តដ៏ថ្លៃថ្នូរខ្ពង់ខ្ពស់ ។

២– ការកខ្វក់ ជាសញ្ញាមួយរបស់ចិត្តដែលខ្វះសេចក្តីខ្នះខ្នែង គឺចិត្តទន់ ចិត្តគគ្រើម ចិត្តថោកទាប ។ គេឲ្យឈ្មោះថាជាចិត្តឥតអៀនខ្មាស ។ ចិត្តទាំងនេះ ជាចិត្តមានកំហុសយ៉ាងធំ ។

អធិប្បាយថា: មនុស្សណាដែលមានបាបគ្រោះបានទទួលអំពើអាក្រក់ គឺទំលាប់ខ្ជីខ្ជា ចិត្តកខ្វក់ទាំងខ្លួនកខ្វក់របស់បុគ្គលនោះឯង តែងនាំមកនូវសេចក្ដីអៀនខ្មាស ។ ប្រាជ្ញាក៏រឹតថមថយ ចិត្តក៏ថោកទាប ព្រោះការសុខចំរើន ធ្លាក់ចុះរលាយបាត់ទៅហើយ ប្រៀបដូចជាផ្កាស្រពោនមិនមានរស្មី ។

៣– ដើម្បីទាំងថែរក្សាចិត្តឲ្យបានបរិសុទ្ធិល្អ គេត្រូវចៀសវាងចាកឱកាសគ្រោះថ្នាក់ គឺការខ្ជីខ្ជាទាំងការមិនធ្វើ ។

អធិប្បាយថា: ដូចជាមនុស្សស្ងៀមមិនធ្វើការសោះ ក៏នាំមកនូវសេចក្ដីឈឺចាប់; ចិត្តអ្នកនោះឯងក៏ធ្លាក់ទៅក្នុងសភាវគតិដ៏ថោកទាប; មនុស្សមានចិត្តប្រឡាក់ដោយមន្ទិលសៅហ្មង គឺសៅហ្មងទាំងចិត្ត សៅហ្មងទាំងកាយ ។

៤– ដូច្នេះ គុណសម្បត្តិដ៏បរិសុទ្ធជាគ្រឿងនាំមកនូវសេចក្ដីរាប់អានទាំងសេចក្ដីថ្លៃថ្នូរ ។

អធិប្បាយថា: ត្រូវចៀសវាងរាល់ឱកាសដែលនាំមកនូវគ្រឿងមន្ទិល មារយាទសៅហ្មងបែបនេះ ក៏ត្រូវកុំសេពគប់ ឬកុំនិយាយ

ភាប់រក ។

(ឧទាហរណ៍អំពីការសំអាតខ្លួន មាននិយាយពិស្តារនៅខាងមុខ សុំឲ្យគ្រូលើកឧទាហរណ៍ផ្សេងៗ មកពន្យល់កូនសិស្សតទៅទៀតផងចុះ) ។

ចោទ.សួរ.. ដូចម្តេចដែលហៅថាសេចក្តីបរិសុទ្ធ? មានឧបការៈយ៉ាងណា? មនុស្សមានគុណសម្បត្តិ គួរជាទីទទួលនូវរង្វាន់ខាងខាងដូចម្តេចឬទេ? ចិត្តកខ្វក់ជាសញ្ញាដូចម្តេច គឺនាំឲ្យគេសំគាល់ដូចម្តេច? តែងទទួលទុក្ខទោសដូចម្តេចខ្លះ? រាយឧកាសខ្លះដែលត្រូវចៀសវាងចេញ? ខ្លួនអ្នកវិញតើអ្នកត្រូវប្រតិបត្តិដូចម្តេច?

* * * *

## មេរៀនទី ២៨ អនាម័យ, ការសំអាត, ការហាត់ប្រាណ.

### Hygiène, Propreté, Gymnastique

អនាម័យ ជាក្បួនរួបរួមនិយាយពីការប្រុងប្រយ័ត្នក្នុងការថែទាំសេចក្តីសុខសប្បាយរាងកាយ ។ មនុស្សជាច្រើន ដែលមានជម្ងឺឈឺថ្កាត់មិនបានសេចក្តីសប្បាយរាងកាយ ក៏មកតែពីការមិនចេះក្បួនអនាម័យឬមិនប្រតិបត្តិឲ្យត្រឹមត្រូវតាមអនាម័យ ។

អធិប្បាយថា: អនាម័យនេះ ត្រូវតែយើងហាត់ទម្លាប់ធ្វើតាំងពី

ក្មេងទៅ, ដោយលេងល្បែងផ្សេងៗ, ដោយការហាត់ដើរ និងការហាត់ប្រាណ ដើម្បីកុំឲ្យខូចខ្លួន ។

ការសំអាតកាយ មិនមែនធ្វើខ្លួនឲ្យនរណាមើល ដូចមនុស្សច្រើនគ្នាគិតនោះទេ, ការសំអាតខ្លួន សំអាតខោអាវ ផ្ទះសម្បែង គឺធ្វើដើម្បីឲ្យបានស្រួលខ្លួន ហើយជាការគោរពដល់ខ្លួនដែលជាមនុស្សជាតិផង ។

## ការសំអាតនឹងអនាម័យ

យើងរាល់គ្នាប្រឹងសំអាតខ្លួន ប្រតិបត្តិធ្វើតាមអនាម័យ ដើម្បីប្រយោជន៍ឲ្យស្រួលខ្លួន ។

១– ត្រូវសំអាតខ្លួន ដុសលាងក្អែលដែលអាចស្ទះទប់រន្ធរោម មិនឲ្យស្បែកដកដង្ហើមកើត និងឲ្យញើសចេញស្រួល, ត្រូវដុសលាងឲ្យញឹកញយ, ត្រូវសំអាតដៃ ជាងផ្នែកខ្លួនឯទៀតទាំងអស់ ។

២– ត្រូវសំអាតសំពត់អាវដែលប្រើផ្ទាល់សាច់ ជាងសំពត់ឯទៀត ។

៣– ត្រូវសំអាតផ្ទះសម្បែងទីលំនៅ, មិនត្រូវទុករបស់គគ

អំពើ ដែលនាំឲ្យមានធុលីនឹងសម្រាមមកកកកុញ ដែលជាហេតុនាំឲ្យពិបាកថែ ។

៤– ចំពោះរូបកូនសិស្ស ត្រូវបន្ថែមការសំអាតសៀវភៅនឹងបន្ទប់រៀនទៀត លើការសំអាតខ្លួននិងការសំអាតខោអាវ ។

៥– ប៉ុន្តែត្រូវដឹងថា មិនគ្រាន់តែសំអាតខ្លួន ខោអាវ ផ្ទះសម្បែង បន្ទប់រៀន សៀវភៅ ។ល។ ដើម្បីនឹងការពារជម្ងឺផ្សេងៗ ហើយធ្វើខ្លួនឲ្យបានសុខស្រួលប៉ុណ្ណោះទេ, ត្រូវប្រឹងធ្វើឲ្យសេចក្ដីសុខស្រួលបានឋិតថេរដើម្បីនឹងឲ្យរីករឹតតែចំរើនឡើងៗ ដោយការប្រព្រឹត្តិហាត់ប្រាណនឹងកីឡាផង ។

ការសំអាត មិនមែនឲ្យបានត្រឹមតែការស្រួលប៉ុណ្ណោះឡើយ គឺដើម្បីជាការគោរពដល់ខ្លួននឹងអ្នកដទៃផង ។

ការសំអាតលោកទុកជាការគោរពខ្លួន ។ បើយើងសំអាតវត្តខាងក្រៅ, គំនិតយើងខាងក្នុងក៏ស្អាត យើងមិនអាចដើម្បីគិតធ្វើផេសផ្ដាសឡើយ ។ មេផ្ទះស្អាត, មនុស្សឯទៀតក្រៅផ្ទះឃើញក៏ញញើត ហើយគោរពវិញ ។

ការសំអាតខ្លួន លោកទុកជាការៈគារពអ្នកដទៃ ៗ បើយើងទទួលភ្ញៀវទាំងខ្លួនកខ្វក់ទាំងសម្លៀកបំពាក់មិនគប្បី ឃើញថាយើងមិនរវល់ទឹងគេ ឃើញថាយើងមើលងាយគេ ៗ ខ្លួនយើងធ្លាប់កខ្វក់ មិនមានទាស់អ្វីទឹងកខ្វក់នោះឡើយ, ប៉ុន្តែអ្នកដទៃមិនអាចអត់ធន់ទឹងក្លិនអាក្រក់នោះទេ ៗ

ការបំអាតនាំឲ្យមានកិរិយាមារយាទល្អ សេចក្ដីទំលាប់ខ្លួនឲ្យចេះសំអាតជាកិរិយាប្រពៃ បណ្ដាលចិត្តយើងឲ្យក្លាហាន ឲ្យមានឆន្ទៈប្រសើរ ឲ្យចេះប្រយ័ត្នខ្លាចប៉ះពារទៅលើគ្រឿងមិនស្អាត, បើមានប៉ះពាល់ទៅលើគ្រឿងកខ្វក់ហើយ នាំឲ្យប្រញាប់ធ្វើឲ្យបានស្អាតវិញ ធ្វើឲ្យយើងមានចិត្តមានគំនិតក្លីស្អាត ដែលជាហេតុនាំឲ្យបំពេញតែការកុសល. ៗ

កូនសិស្សមានទំលាប់ស្អាត ស្អាតទាំងកាយស្អាតទាំងចិត្ត, ក្នុងការបំពេញករណីយកិច្ច ក៏តែងបំពេញដោយចិត្តស្មោះត្រង់គ្មានលួចឡើយ ៗ

អ្នកដំនួញមានទំលាប់ស្អាត មិនអាចប្រព្រឹត្តអាក្រក់យក

ចំណេញឲ្យហួសកំណត់អំពីអ្នកទិញឡើយ ។

កម្មករមានទំលាប់ស្អាត ច្រើនបំពេញការងារដោយទៀងត្រង់ ទៀងទាត់តាមពេលវេលា ហើយឥតមានបំភាន់គេឡើយ ។

ការសំអាតធ្វើឲ្យយើងមានវាចាពីរោះ មានពាក្យល្អពាក្យសុចរិត ហើយនាំឲ្យយើងមិនចេះពោលពាក្យគំរោះគំរើយនិងពាក្យផ្ការៗ

ដោយហេតុនេះហើយ បានជាមានពាក្យសុភាសិតថា :

## ភាសិត-បិត្ត

សេចក្តីសុខសប្បាយមិនមានរោគ ចេញមកពីការប្រុងប្រយ័ត្នជាឱសថ ។

ការសំអាតរបស់មនុស្ស ដូចជាគ្រឿងក្រអូបរបស់ផ្កាដែរ ។

ការបរិសុទ្ធរបស់ចិត្ត ដូចជាការស្អាតរបស់រាងកាយដែរ ។

អ្នកចង់ដឹងថាជាតិណាមួយស៊ីវិល័យ, ត្រូវសួរ តើគេចំណាយសាប៊ូច្រើនឬ ?

កិច្ចការទាំងពួងក្នុងលោកនេះ មានកិច្ចការល្អជាដើម មានតែសេចក្តីសុខសប្បាយរាងកាយទេ ដែលជាគ្រឿងប្រកប ។

ខ្វះការហាត់ប្រាណ កីឡា ទុកដូចជាថ្នាំអាសិរពិសដែលនាំបន្ថយអាយុ ។

ចិត្តបរិសុទ្ធ តែងមានក្នុងខ្លួនដែលសុខសប្បាយ ។

ដើម្បីឲ្យបានសម្រេចផលបែបនេះបាន តោងយើងដាក់គំនិតដល់កុមារទាំងឡាយ ឲ្យចំណាប់តាមអនាម័យនឹងការហាត់ប្រាណកុំខាន ។

## ហាត់អាន

## ប្អូនស្រីឡាញ់ទឹក

ការសំអាត ជាការលំអ ជាគ្រឿងអលង្ការរបស់ក្មេង អាចកែរូបអាក្រក់របស់យើងឲ្យល្អបាន ។ ដូច្នេះចូរគោរពការសំអាតដូចជាគេគោរពវត្ថុដែលគេត្រូវគោរពដែរ ។

កុមារទាំងឡាយអើយ, ទោះស្រីក្រមុំក្មេងកំឡោះ នឹងសត្ត-និករទាំងអស់ ដែលឋិតនៅលើផែនដីនេះ តោងតែឲ្យស្អាតគ្រប់រូប ទើបបានសេចក្តីសុខសប្បាយរាងកាយ ។ ការសំអាតជាគុណធម៌

របស់រាងកាយ គឺជាកិច្ចដែលមិនត្រូវធ្វេសប្រហែស ។ អ្នកបើកភ្នែក អ្នកៈក្រោកភ្លាមពីដេក អ្នកត្រូវលុបមុខមុនការទាំងពួង ។ ឃើញថាអ្នក ធ្វើខួរក្បាលអ្នក ធ្វើភ្នែកអ្នក ៗ ល ៗ ឲ្យត្រជាក់ ។ ចូរអ្នកស្រឡាញ់ ទឹក គោរពរាប់អានទឹកឲ្យណាស់ ។ អ្នកស្រោចដើមកុលាបរបស់ អ្នក ដូចជាដុសខាត់ផ្ទាល់អ្នក ។ ស្រីដែលរៀបចំខ្លួនល្អ មិនមែន ជាស្រីអាក្រក់ទេ ។ ផ្ទះមិនស្អាត, គេគ្រាន់តែឃើញមាត់ជណ្ដើរ គេស្បថមិនចង់ចូលទៅផង ។

## ពន្យល់ពាក្យ

**សំអាត** កិ. ធ្វើឲ្យស្អាត, ឲ្យអស់មន្ទិល; សំអាតផ្ទះ, សំអាតខ្លួន, សំអាតចិត្ត, បោសសំអាត , ជូតសំអាត ។

**គ្រឿងអលង្ការ** ន. គ្រឿងប្រដាប់សម្រាប់តាក់តែងខ្លួន ។

**ស្បថ** កិ. (ពាក្យក្លាយមកពី ម.សំ. សបថ; ប្រកាសសំបថ គឺពោលពាក្យសច្ចាប្រកាសសេចក្តីពិតត្រង់ខាងខ្លួនចំពោះមុខបុគ្គល ដទៃ : ស្បថតែខ្លួន, ស្បថប្រាំពាន, ស្បថស្បែ ។

ចោទសួរ– អនាម័យដូចម្ដេច? ការប្រតិបត្តិសមដូចម្ដេចខ្លះ? ដូចម្ដេចហៅថាការសំអាត? លុះតែទៅជាអ្នកមានទ្រព្យសម្បត្តិទើបធ្វើខ្លួនឲ្យស្អាតបានឬ? អ្នកសំគាល់ដូចម្ដេចពីមនុស្សកខ្វក់? គ្រោះថ្នាក់របស់វាដូចម្ដេចខ្លះ? ចូរាយខសំអាតដើម្បីធ្វើខ្លួនឲ្យសុខសប្បាយ ។ ម្ដេចក៏ខ្ញុំឲ្យហាត់ប្រាណ?

* * * *

## មេរៀនទី ២៩ ការសន្ដោសនឹងការដឹងប្រមាណក្នុងភោជន

### Sobriété et tempérance.

១–យើងត្រូវការថែទាំនិងជួសជុលកម្លាំងយើងរាល់ថ្ងៃ ដោយអាហារ; តែការបរិភោគអាហារក្នុងការថែទាំកម្លាំងនោះ ត្រូវឲ្យមានការសន្ដោសក្នុងការស៊ីនិងការផឹក ។

អធិប្បាយថា: វេលាបរិភោគអាហារម្ដងៗ ត្រូវបែកបម្រូបអាហារតាមការគួរសម ដើម្បីឲ្យបានសេចក្ដីសុខសប្បាយ ដើម្បីកុំឲ្យអវយវៈអស់កម្លាំងពេក ។ ហេតុនេះពួកអ្នកបួសមានតាបសឥសីជាដើម តែងមានសន្ដោសក្នុងការបរិភោគ ច្រើនតែប្រើប្រាស់បាយឬមើមឈើនិងផ្លែឈើជាដើមប៉ុណ្ណោះ ។ ពួកតាបសឥសីទាំងនោះច្រើនបានសេចក្ដីសុខស្រួលហើយមានអាយុវែងផង ។

២-មនុស្សលោភ គឺមនុស្សគ្មានការសន្ដោសក្នុងភោជនាហារ ផឹកស៊ីទៅតាមបំណងឃ្លាន គឺជាមនុស្សលោភស៊ី ៗ ជនណាផឹកស៊ីជ្រុលនឹងធ្លាក់ខ្លួនទៅជាមនុស្សស្រវឹង ៗ

អធិប្បាយថា: មនុស្សច្រើនតែលោភក្នុងការបរិភោគអាហារ ដែលនាំឲ្យគ្រឿងកិនអាហារ មានក្រពះនឹងពោះវៀនជាដើមមានការនឿយហត់ច្រើន ៗ បំណែកខាងសត្វមានគោក្របីជាដើមពុំសូវលោភក្នុងអាហារទេ ៗ

៣-មនុស្សលោភក្នុងការបរិភោគបង្អែមជាដើមនាំឲ្យខូចខ្លួន ៗ

អធិប្បាយថា: មនុស្សដែលចូលចិត្តគ្រឿងស្ករ ឬ នំផ្សេង ៗ ដែលមានជាតិស្ករច្រើន ហើយបរិភោគហួសប្រមាណ; ក្រពះអ្នកនោះឯងនឹងខូចបន្តិចម្ដង ៗ នាំមិនឲ្យទទួលអាហារធម្មតាបាន បណ្ដាលឲ្យទៅជាមិនមានសេចក្ដីសប្បាយក្នុងខ្លួន ៗ

៤- គេមិនត្រូវបរិភោគអាហារដើម្បីរស់នៅសម្រាប់តែស៊ីផឹកនោះទេ ៗ ភាសិតនេះជាច្បាប់បុរាណសម្រាប់មនុស្សទូទៅ ៗ ហេតុនេះ ការស៊ីផឹកមិនត្រូវឲ្យហួសប្រមាណតាមសេចក្ដីឃ្លាននោះទេ ៗ

អធិប្បាយថា: យើងមិនត្រូវស៊ីផឹកឲ្យហួសប្រមាណលើសពីការស្រេកឃ្លាននោះទេ ។ សំដីអ្នកប្រាជ្ញម្នាក់ពោលថា " ខ្ញុំទុកគ្រូពេទ្យបីនាក់ក្បែរខ្លួនខ្ញុំ សម្រាប់ទូន្មានខ្ញុំជានិច្ច គឺ: ការហាត់ប្រាណ១, ទឹក១, និងការសន្តោសក្នុងអាហារ ១" ។

## ភាសិត-បិតា

អាហារមួយ សំលៀកបំពាក់មួយ ជាការចាំបាច់របស់មនុស្ស ។

ចរិយាសាស្ត្រ ប្រៀបដូចជាដើមឈើ ដែលមានឫសដុះចាក់ទៅក្នុងអាកាស មានផ្កាផ្លែ ផ្កាយក្រិននៅលើផែនដី ។

មនុស្សដែលគ្មានសតិសម្បជញ្ញៈ គ្មានគំនិត គ្មានវិចារណ-ញ្ញាណ ទុកដូចជាមនុស្សគ្មានក្រពះបាយ ។

ចោទសួរ – ដូចម្ដេចដែលហៅថា ការសន្តោសនឹងការដឹងប្រមាណក្នុងភោជន ? ដូចម្ដេចខ្លះការបរិភោគអាហារល្អផងគេ ? មនុស្សលោកតែងទទួលគ្រោះថ្នាក់ដូចម្ដេច ? ក្មេងត្រូវទម្លាប់ដូចម្ដេចក្នុងការបរិភោគអាហារដើម្បីចៀសវាងជម្ងឺធំកាត់ ?

# ការអាន

## ល្មោភ គ្មានសេចក្ដីសន្ដោស

មានឆ្មាស្រុក ១ ចាបពូក ១ គេចិញ្ចឹមនៅជាមួយគ្នា ៗ ថ្ងៃមួយ មានចាបព្រៃ ១ ហើរមកទុំក្នុងទីជិតនៃចាបពូកនោះ ហើយពោលពាក្យតិះដៀលចាបនៅក្នុងទ្រុងជាភាសាសកុណជាតិ ៗ ឯចាបនៅក្នុងទ្រុង ក៏កើតទោសោឡើង តាំងជេរប្រទេចទៅចាបព្រៃវិញ ៗ ចាបទាំងពីរកើតជម្លោះជេរគ្នាទៅវិញទៅមក, តែនឹងប្រចឹតគ្នាពុំបាន ព្រោះមួយនៅក្នុងទ្រុង មួយនៅក្រៅទ្រុង ៗ ឯឆ្មាស្រុកបានឮចាបទាំងពីរឈ្លោះគ្នាដូច្នោះ ក៏ខឹងនឹងចាបព្រៃថា អាសត្វចង្រៃ ហេតុអ្វីក៏មកឈ្លោះប្រកែកនឹងចាបជាសំឡាញ់អញអេះ! បើដូច្នេះ អញនឹងជួយចាបជាសំឡាញ់ចុះ, គិតហើយឆ្មានោះលបទៅចាប់ចាបព្រៃនោះបាន ហើយទំពាស៊ីសាច់ចាបព្រៃកើតក្ដីឆ្ងាញ់ពិសា ទើបគិតថា "អញមិនដឹងជាសាច់ចាបព្រៃមានរសជាតិឆ្ងាញ់ដល់ម្ល៉េះសោះ, បើដូច្នេះ ចាប់ផ្ដើមតាំងពីថ្ងៃនេះទៅ អញនឹងស្វែងចាប់ចាបព្រៃអាស្រ័យ

ជាចំណីខ្លួន", ខ្លានោះគិតផ្ទុចត្រោះហើយ, ពីថ្ងៃនោះមក តាំងតែស្វែង លបចាប់ចាបតែត្រ អាស្រ័យជានិរន្តរ៍ ៗ ថ្ងៃមួយ ខ្លានោះរកចាប ចាបតែត្រពុំបាន កើតញ៉ាមមាត់អត់មិនបាន ទើបហែកទ្រុងចូលទៅ ចាប់ចាបជាសម្លាញ់ បរិភោគតាមក្ដីប្រាថ្នាខ្លួនហោង ៗ

* * * *

## មេរៀនទី៣០ ជម្ងឺស្រា - អាភៀន

## L'alcoolisme—Opium



១- ជម្ងឺស្រាជាអាវុធទុកដូចជាជម្ងឺពិស ទុព្ភិក្ស និងសង្គ្រាម យ៉ាងសាហាវ សម្រាប់ប្រហារមនុស្ស ។

អធិប្បាយថា: ស្រាជាថ្នាំពុលមួយ ។ ទឹកស្រវឹងតាំងឡាយ មានកូញ៉ាក់ រេម អាប់ស្សេន ស្រាទំពាំងបាយជូរ ស្រាត្នោត ជាដើម ទុកណាជាផឹកបន្តិចម្តងៗ ជាទំលាប់ ក៏គង់នាំឲ្យពុល អវយវៈខ្លួន ហើយនឹងបំផ្លាញរូបកាយយ៉ាងរហ័សទៅបាន ។ គ្រឿងស្រវឹង ហៅថាមេសេចក្តីស្លាប់ ។

២- អ្នកប្រមឹកច្រើនមានជម្ងឺធ្ងន់ផ្សេងៗ ហើយជាជម្ងឺមើលមិនជា ។ ជម្ងឺដែលធំជាងគេហើយតែងកើតញឹកញយ គឺជម្ងឺរបេង ។

អធិប្បាយថា: គេបានសង្កេតឃើញក្នុងមនុស្សដែលស្លាប់នឹងជម្ងឺរបេងមួយរយនាក់ មាន ៨០ នាក់ ដែលបណ្តាលមកពីជម្ងឺស្រាអាភៀន ។ មនុស្សប្រមឹកច្រើនខូចក្នុងនឹងអាយតនៈ ៥ ។ ប្រាជ្ញានឹងចិត្តគំនិតនឹងថមថយទៅជាលំដាប់, ធ្វើការអ្វីពុំកើត ទុកដូចជាមនុស្សឆ្កួតហើយអាយុខ្លី ។ ឯជម្ងឺអាភៀន ដូចជាជម្ងឺស្រាដែរ ។

៣ – មនុស្សប្រមឹកនឹងអ្នកជក់អាភៀន ជាមនុស្សសាហាវក្នុងគ្រួសារ ។

អធិប្បាយថា: កាលណាមនុស្សនេះស្រវឹង រមែងមានការជេរវាយដំមនុស្សជិតខាងខ្លួន បណ្ដាលទៅជាទោសផ្សេង ៗ មានទោសឧក្រិដ្ឋជាដើម ។ ម្យ៉ាងទៀត ធ្វើឲ្យប្រពន្ធកូនគ្រួសាររបស់ខ្លួនមានសេចក្ដីរងទុក្ខ ដោយគ្មានសង្ឃឹមថាជាមេផ្ទះបាន ហើយនាំបណ្ដាលឲ្យកូនចៅធ្លាក់ទៅក្នុងជម្ងឺស្រវឹងតពូជទៅទៀតផង ។ កូនអ្នកប្រមឹក កើតមកច្រើនមានអាការខ្រែមខ្រមលីលា ហើយទៅជាអ្នកប្រមឹកទៀត ។

៤–ដូច្នេះ ត្រូវយើងកុំទម្លាប់ផឹកស្រាជក់អាភៀន ទុកណាជាមានគេហៅទៅស៊ីលៀងក៏ដោយ ។ ម្យ៉ាងទៀតសូម្បីបារីក៏កុំទំលាប់ជក់ដែរ ព្រោះជក់ថ្នាំក៏នាំឲ្យពុលខ្លួនស្រដៀងគ្នានឹងស្រាដែរ ។

ណែនាំ– សូមឲ្យគ្រូលើករឿងមនុស្សស្រវឹងយកមកពន្យល់កូនសិស្សជាឧទាហរណ៍តទៅទៀតផង ។

ចោទសួរ – អ្នកយល់ដូចម្ដេចពីមនុស្សប្រមឹក? មនុស្សប្រមឹកទទួលគ្រោះថ្នាក់ដូចម្ដេចខ្លះ? ចំពោះខ្លួននឹងចំពោះគ្រួសាររបស់ខ្លួនយើងត្រូវប្រតិបត្តិដូចម្ដេចចំពោះស្រានិងបារី?

## ការបញ្ជាក់ឡើងវិញ ការដាក់ឲ្យធ្វើ

១– អ្វីគេហៅថាកុហក ? គេពោលពាក្យកុហក ?

២– ដើម្បីអួតអាងលើកដំកើងខ្លួន, ដើម្បីអំពើជាមនុស្សខាតលក្ខណ៍, ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន, តើពាក្យកុហកទាំងនេះអ្នកយល់ដូចម្ដេច ?

៣– ចូរអធិប្បាយពីប្រយោជន៍សុចរិតទៀងត្រង់ ដែលជាគុណសម្បត្តិដ៏ល្អជាជាងការកុហកដែលជាអំពើលាមក ?

៤– សេចក្ដីយល់ឃើញរបស់អ្នកដូចម្ដេចពីភាសិតថា: "ត្រូវធ្វើឲ្យគេសរសើរ តែត្រូវគេចវេះចេញឲ្យឆ្ងាយ" ? (ឆ្លើយ : ធម្មតាមនុស្សយើងតែងស្រឡាញ់ការសរសើរ ការគប់រក ទឹងគេក្ដីឈ្មោះល្អពីរោះពីសា, តែបានជាលោកថាឲ្យគេចវេះចេញ ដ្បិតថាការសរសើរតែងជាគូគានឹងពាក្យទិន្នាផង, មនុស្សខ្លះលង់ដោយការ

សរសើរ ហេតុដល់ក្មេងខ្លួនឡើងជាផុងគំនិតប្រព្រឹត្តកើតកើនខុស ទំនងក្អាត់ស្មៀតកំមាន, បានជាលោកឲ្យបៀសវាងខ្លះចេញ កុំឲ្យត្រឡប់ទៅជាបានការអាប់យសវិញ) ។

៥- អ្វីហៅថាក្លាហាន? ក្លាហានមានប៉ុន្មានយ៉ាង? ចូរទាញឧទាហរណ៍ខ្លះមកមើល ដែលអ្នកធ្លាប់ដឹងឃើញ ។

៦- ចូរអធិប្បាយភាសិតថា "ធ្វើការអ្វីធ្វើទៅតាមសម្រួល កុំប្រញាប់ស្រួកពន់ពេក" ឬថា "សន្សឹមកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា" ។

៧- កុលបុត្រត្រូវធ្វើដូចម្ដេចខ្លះ ចំពោះមិត្រភក្តិ?

៨- បងប្អូនអ្នកម្នាក់ត្អូញត្អែរពីការលំបាកទាំងឡាយ ៗ ចូរអ្នកពន្យល់ថា ត្រូវព្យាយាមរំលងឧបសគ្គនេះឲ្យម៉ឺងម៉ាត់ទើបរួចបាន ។

៩- ប្អូនស្រីអ្នកម្នាក់ ធុញទ្រាន់នឹងចៅហ្វាយនាយប្រិតប្រៀនពីការសំអាត ។ ចូរអ្នកពន្យល់ថា ការត្អូញត្អែរនេះជាគំនិតខុស ត្រូវតែប្រកាន់ការសំអាតនេះទុកជាគោលគតទៅ ។

១០ – ចូរអធិប្បាយពីការសំអាត, ក្បួនអនាម័យ, ពីការសន្តោស, ពន្យល់ពីទោសដែលមិនប្រតិបត្តិតាមក្បួនទាំងនេះ ។

១១– ចូរសំដែងពីទោសស្រា អាភៀន ដែលធ្វើខ្លួនឲ្យថយថោកទឹងឲ្យអាយុខ្លី ។

# ជំពូក ៥

# Chapitre 5

## ទ្រព្យខាងក្រៅ

## Les biens extérieurs

មេរៀនទី ៣១

### ការងារ

### Le travail



១– ការងារជាច្បាប់សម្រាប់សព្វសត្តនិករ ដែលរស់នៅលើផែនដីលោកសន្និកស ទាំងមូល ជាកេដជាង យ៉ាងសម្បើម ដែលសត្វទាំងអស់តែងបំពេញកិច្ចការ ៗ តាំងពីសត្វពីងពាងតូចដែលត្បាញ

សំណាញ់របស់វា រហូតដល់មនុស្សលោក ដែលជាជាងអ្នកសង់គេហដ្ឋាន ប្រាសាទ ឬអ្នកធ្វើរបរកសិកម្ម ឬអ្នកតែងសៀវភៅជាដើម សុទ្ធតែជាអ្នកមានការងារចាំបាច់មួយយ៉ាងសំខាន់ ៗ គឺមកពីគេធ្វើការងារនេះឯងហើយ បានជាគេអាចប្រមូលទ្រព្យពីខាងក្រៅមកចិញ្ចឹមជីវិតខ្លួនបាន គឺយកមកសង់ផ្ទះសំបែង ទិញអាហារភោជនទឹងសំលៀកបំពាក់ ៗ ការងារជាករណីយកិច្ចមួយ ព្រោះជាមនុស្សយើងកើតមកត្រូវតែធ្វើការងារ ៗ ការងារជាការសប្បាយមួយ តែមិនឲ្យអផ្សុកចិត្ត នាំឲ្យកើតភោគទ្រព្យដែលខ្លួនត្រូវសោយក្នុងការសម្រាក ៗ

២– ការងារមានពីរយ៉ាង គឺការងារខាងផ្លូវបញ្ញា ១ ការងារខាងផ្លូវដៃ ១ ៗ ការងារទាំងពីរមុខនេះសឹងសុទ្ធតែល្អប្រពៃ ព្រោះជាកិច្ចដែលត្រូវបំពេញហើយនាំមកនូវប្រយោជន៍ ៗ ការងារខាងផ្លូវបញ្ញា មើលមួយភ្លែតទៅហាក់ដូចជាខ្ពង់ខ្ពស់ជាងគេ ៗ ឯការងារខាងផ្លូវដៃ ជាការសម្រាប់បំពេញបំណងដែលយើងត្រូវការខានមិនបាន ៗ ដ្បិតថាមនុស្សយើងចៀសវាងបានតែកាព្យឃ្លោង ភ្លេងគូរ

គ្រឿង ។ល។ តែទឹងចៀសវាងគោងនាហារ សំលៀកបំពាក់ ផ្ទះ សំបែងពុំបានជាដាច់ខាត ។

៣- មនុស្សឧស្សាហ៍តែងនាំមកនូវសេចក្តីពប់រក; មនុស្សខ្ជិលគេតែងចៀសវាង; មនុស្សកំជិលផេះឃើញកិច្ចការទាំងពួងថាលំបាកទាំងអស់; ម្ល៉ោះហើយច្រើនតែធ្លាក់ខ្លួនជាមនុស្សទល់ក្រ ជាមនុស្សឥតប្រយោជន៍, កើតមកនាំឲ្យធ្ងន់តែផែនដី, ឥតបានការអ្វីជាប្រយោជន៍ដល់គ្រួសារបស់ខ្លួន នឹងប្រទេសជាតិមាតុភូមិ ថែមទាំងជាអ្នកបំផ្លាញលោកទៀតផង ។

៤- កុមារទាំងឡាយអើយ ! ក្នុងសាលារៀន បាទាំងឡាយត្រូវធ្វើខ្លួនឲ្យជាអ្នកឧស្សាហ៍ ព្រោះថាមានតែការអ៊ារនេះឯងហើយដែលនាំអ្នកទាំងឡាយទៅកាន់សេចក្តីសុខ ឲ្យមានកេរ្តិ៍ឈ្មោះយសសក្តិហើយឲ្យបានស្ថិតនៅជាស្រួលតទៅ ។ អ្នកចូលមើលជុំវិញខ្លួនអ្នក, សូម្បីសត្វទាំងឡាយ ក៏គ្មានខ្ជិលច្រអូសឈប់ឈរនៅស្ងៀមឡើយ, ស្រមោចក្តី កណ្តៀរក្តី តែងពូនដី, ឃ្មុំត្រាច់ទៅរកលំអងផ្កាយកមកធ្វើទឹកកាវ ។

# ការគោរពទ្រព្យ

ទ្រព្យចែកចេញជា ២ យ៉ាងគឺ: ទ្រព្យផ្ទាល់ខ្លួនដែលបានកើតមកពីកំឡាំងខ្លួនខំរក និងទ្រព្យសាធារណប្រយោជន៍ គឺទ្រព្យរាជការដែលជាសម្បត្តិរបស់ប្រទេសនៃយើងគ្រប់គ្នា ។

វត្ថុឯណា ដែលជាទ្រព្យរបស់យើងៗ ត្រូវទុកឲ្យគង់នៅល្អ ព្រោះទ្រព្យទាំងនោះជាផលនៃការដែលយើងធ្វើដោយកំឡាំង និងផលនៃការខំសំចៃរបស់យើង ។

វត្ថុឯណា ដែលជាទ្រព្យសាធារណប្រយោជន៍ ក៏យើងត្រូវតែថែទាំទុកឲ្យគង់ដែរ ។ ប្រាក់ដែលរាជការចំណាយទៅសាងសាលារៀន ផ្លូវថ្នល់ សួនច្បារ មន្ទីរបាត់ការផ្សេងៗ មិនដឹងជាអស់ប៉ុន្មានលានរៀលទេ, ប្រាក់នេះបានមកពីថវិកាជាតិ គឺប្រាក់របស់ប្រជាជាតិ ទុកដូចជាប្រាក់កាសយើងដែរ ។ ហើយើងបំផ្លាញទ្រព្យរាជការ, ទុកដូចជាបំផ្លាញទ្រព្យរបស់ប្រជាជាតិយើង រដ្ឋយើង ប្រាក់យើង ។

ទីសំចតសប្បាយជារបស់សាធារណៈ ក៏ត្រូវតែយើងចូលទៅសំចតលេង កុំធ្វើឲ្យកខ្វក់ឬបាក់បែក, ត្រូវតែគិតដល់អ្នកដទៃដែលនឹងចូលមកសំចតក្រោយយើងផង ។

ទ្រព្យដទៃទៀត ទោះបីមិនមែនជាទ្រព្យផ្ទាល់ខ្លួនឬទ្រព្យរដ្ឋការ ដូចជាកេងម៉ាស៊ីនទឹកនិងភ្លើង អយស្ម័យយាន ឃ្លាំងទំនិញរបស់ឯកជន ឬរបស់សមាគមជាដើម ក៏ត្រូវតែយើងកុំធ្វើឲ្យខូចខាតដែរ ព្រោះថាបើយើងបំផ្លាញរបស់ទាំងនេះហើយ សេចក្ដីសុីវិល័យ សេចក្ដីចេះដឹង និងវឌ្ឍនធម៌របស់ប្រទេស ឈ្មោះថាធ្វើដំណើរថយក្រោយទៅរកឋានៈដ៏ថោកទាបជាប្រាកដ ។

## ត្រូវស្រឡាញ់ការងារ

១- ហេតុអ្វីបានជាយើងត្រូវធ្វើការ? ការងារជាករណីយកិច្ចរបស់យើងផង ជាការសប្បាយផង ។ ការងារជាករណីយកិច្ចទី១របស់មនុស្ស គឺមនុស្សត្រូវធ្វើការចិញ្ចឹមជីវិត ។ មួយទៀតត្រូវធ្វើការដើម្បីឲ្យបានរស់នៅក្នុងឋានៈដ៏ខ្ពង់ខ្ពស់ ហើយដោយសេរីផង, ត្រូវធ្វើការឲ្យកូនចៅបានរស់នៅក្នុងទីជាសុខ ដោយឥតមានទុក្ខភ័យ

បារម្ភនឹងការអត់ឃ្លាន ៗ ការងារអាចឲ្យយើងសប្បាយ ព្រោះថាបើយើងខំធ្វើការ ខំរៀនសូត្រ យើងនឹងសប្បាយ ដោយបានចំរើនខាងចំណេះវិជ្ជា ដោយបានយល់កិច្ចការផងទាំងពួង នឹងដោយបានបង្កើតអ្វីផ្សេងៗកើត ៗ សិស្សមិនត្រូវធ្វើការដោយសារតែមានសេចក្តីខ្លាចគ្រូ ឬចង់ប្រជែងប្រណាំងនឹងគូកនតែប៉ុណ្ណោះទេ ព្រោះថាបើយើងធ្វើការដោយសារតែខ្លាចគ្រូ ការងារនោះនឹងក្លាយទៅជាទណ្ឌកម្មវិញ ៗ ឯការប្រជែងប្រណាំង អាចឲ្យយើងមានចិត្តអាក្រក់ឥច្ឆាឈ្នានីសគ្នាទៅវិញទៅមក ៗ មនុស្សខ្ជិលជាមនុស្សរងទុក្ខវេទនាហើយច្រើនជាមនុស្សមានជម្ងឺផង ៗ សេចក្តីខ្ជិលច្រើនតែបណ្តាលមកអំពីអ្វីមួយ; បើយើងមើលជម្ងឺនោះជា. សេចក្តីខ្ជិលក៏វិនាសទៅបាត់ឯង ៗ មនុស្សខ្ជិលច្រើនតែមានអនាគតអាប់ឱន ៗ

៤– យើងត្រូវធ្វើការបែបណា ? យើងត្រូវរៀនធ្វើការ ព្រោះថាបើយើងមិនចេះធ្វើការទេ, យើងនឹងខាតពេលអស់ជាច្រើន ៗ ដើម្បីនឹងធ្វើការបានស្រួល ត្រូវកំណត់ការដែលយើងត្រូវធ្វើទុកជាមុន ត្រូវរៀបចំប្រដាប់ប្រដាដាក់ជិតដៃ កុំឲ្យពិបាកក្រោកទៅយក

នាំឲ្យខាតពេល ត្រូវចាប់ធ្វើការឲ្យមាំមួនកុំឲ្យចិត្តរាយមាយ សំចៃពេលហើយត្រូវព្យាយាមធ្វើការនោះ លុះត្រាតែហើយ ។

៣– របៀបប្រើគុណសម្បត្តិរបស់យើង ។ គុណសម្បត្តិដែលយើងយកមកប្រើជាងគេក្នុងពេលធ្វើការ គឺសេចក្ដីប្រយ័ត្នមួយ នឹងស្មារតីមួយ ។

សេចក្ដីប្រយ័ត្នអាចឲ្យយើងដឹងច្បាស់ថា ការរបស់យើងពិបាកនៅត្រង់ណាខ្លះ ។ ស្មារតីប្រៀបដូចជានាយឃ្លាំងម្នាក់ សម្រាប់ត្រួតត្រាមើលឃ្លាំងចំណេះវិជ្ជាយ៉ាងធំដែលយើងរកបានមក, បើក្នុងឃ្លាំងនោះមានរបស់ដាក់រាត់រាយពាសពេញដេរដាស, នាយឃ្លាំងមិនអាចរកឃើញរបស់ដែលត្រូវប្រើឲ្យបានរហ័សទាន់ចិត្តទេ ។ ដូច្នេះត្រូវរៀបចំរបស់ក្នុងឃ្លាំងនេះ ឲ្យមានរបៀបសម្រាប់ធ្វើការ ។

ចោទសួរ–ដូចម្ដេចបានជាការងារហៅថាការចាំបាច់និងជាករណីយកិច្ច ព្រមទាំងជាសេចក្ដីសប្បាយរបស់មនុស្ស ? ការងារមានប៉ុន្មានយ៉ាង ? សេចក្ដីយល់ឃើញដូចម្ដេចក្នុងការងារនីមួយៗ ? ចូរធ្វើតំនួររូបសណ្ឋានរបស់មនុស្សខ្ជិល, អនាគតរបស់វាដូចម្ដេច ? ដល់កាលណាទើបចាប់ស្រឡាញ់ការងារ? ការងារហុចប្រយោជន៍អ្វីខ្លះ?

## មេរៀនទី ៣២ សម្រាក សប្តាហៈ

## Le repos hebdomadaire.

១–មនុស្សយើងមិនត្រូវធ្វើការឥតឈប់ឈរដូចគ្រឿងម៉ាស៊ីននោះទេ, ត្រូវមានឈប់សម្រាកយ៉ាងតិច ១ ថ្ងៃ ក្នុងមួយអាទិត្យ; បើពុំដូច្នោះទេ, នឹងទៅជាឈឺពិកពិការហើយនឹងឆាប់ចាស់ផង ។

អធិប្បាយថា: គេបានសង្កេតទៅឃើញថា កម្មករដែលនឹងធ្វើការទៅបានស្រួលខ្លួនផង លុះតែបានឈប់សម្រាក ១ ថ្ងៃ ក្នុងមួយអាទិត្យ, សូម្បីតែសត្វទឹម ក៏ត្រូវបានការសម្រាក ក្នុង ៥ ថ្ងៃឲ្យសម្រាក ១ ថ្ងៃ ទើបគួរ ។ ហេតុនេះ ទើបទម្លាប់អ្នកកាន់ព្រះពុទ្ធសាសនា ក្នុងមួយអាទិត្យត្រូវឲ្យសម្រាក ១ ថ្ងៃ ក្នុងថ្ងៃសីល ដើម្បីជាការលំហែខ្លួនផង ដើម្បីនឹងបានទៅធ្វើសីលទានផង ។ ច្បាប់នេះជាប់ជាបវេណីរៀងរបមក ។ ហេតុនេះ យើងគួរឆ្លៀតសម្រាក ដើម្បីទៅវត្តអារាមទទួលសីលធ្វើបុណ្យទាន ទើបសមជាអ្នកកាន់ព្រះពុទ្ធសាសនា ។

២– ត្រូវសំចៃពេលឈប់សម្រាកនេះ តាំងចិត្តឲ្យស្អាត ទទួល

សីលធ្វើបុណ្យទាន ទៀតទៅសាកសួរធម៌អាថ៌ចំពោះលោកអ្នកប្រាជ្ញ មានលោកសង្ឃជាដើម ដែលលោកជាអ្នកណែនាំយើងឲ្យបានល្អ , ទៀតមើលសៀវភៅ, ដើរលេងលំហើយខ្លួនខ្លះ ៗ កុំណែពេលនេះ ទៅប្រព្រឹត្តការសប្បាយដោយល្បែងឥតប្រយោជន៍ឡើយ ។

ចោទសួរ - ហេតុដូចម្តេចបានជាមនុស្សត្រូវឈប់សម្រាកខ្លះ ? ចំណែកខាងប្រទេសកម្ពុជាយើង ការឈប់សម្រាកនេះ ម្តេចក៏ជាការមានប្រយោជន៍ដល់គ្រួសារ ? ថ្ងៃសម្រាកនេះ យើងត្រូវធ្វើអ្វី ? យើងត្រូវចៀសវាងការអ្វីខ្លះ ?

* * * *

## មេរៀនទី៣៣ របៀប

## L'ordre

ដែលហៅថារបៀបនោះ គឺត្រូវឲ្យមានកន្លែងមួយសម្រាប់របស់មួយ ហើយត្រូវទុកដាក់របស់នោះតាមកន្លែងវា ត្រូវធ្វើការនោះតាមពេល គឺការដែលត្រូវធ្វើថ្ងៃនេះ មិនត្រូវបង្អង់ទុកការនោះដល់ថ្ងៃស្អែក ។

អធិប្បាយថា : ការមានរបៀប នាំឲ្យចំណេញពេលវេលាផង ចំណេញកន្លែងផង ; ដូច្នេះ របៀបជាគុណសម្បត្តិមួយដែលយើង

យកមកប្រើជានិច្ចក្នុងពេលធ្វើការ គឺការប្រយ័ត្នមួយដែលជាគុត្តា ទីនឹងស្មារតី ។ ស្មារតីប្រៀបដូចជានាយឃ្លាំងម្នាក់ សម្រាប់ត្រួតត្រា មើលឃ្លាំង យ៉ាងជាក់របស់ដែលយើងរកបានមក, បើក្នុងឃ្លាំងនោះ មានរបស់ដាក់កក់កាយពាសពេញ, ។ នាយឃ្លាំងមិនអាចរកឃើញ ភ្លាម ៗ ទាន់ចិត្តទេ ។ ដូច្នេះ ត្រូវរៀបចំក្នុងឃ្លាំងនេះឲ្យមាន របៀប សម្រាប់ធ្វើការ ទើបការនោះប្រព្រឹត្តទៅបានរហ័ស ។

## ភាសិត - បិត្ត

របៀបនឹងសំអាត ជារបស់មានតម្លៃនៃអ្នកក្រ ។

របៀបនឹងការចែកពេលវេលាក្នុងថ្ងៃមួយ នាំឲ្យចំណេញ ពេលដែលជាកំណាប់ដ៏ប្រសើរ ។

របៀបមានប្រយោជន៍ច្រើនយ៉ាង គឺ: នាំឲ្យស្រួលចិត្តគំនិត ចំណេញពេលវេលា នាំឲ្យរបស់នោះៗ បានគង់វង់ ។

ចោទសួរ – ដូចម្ដេចហៅថារបៀប? ប្រយោជន៍របស់របៀបនេះដូចម្ដេចខ្លះ? ម្ដេចក៏របៀបនេះជាប្រយោជន៍ដល់ឪពុក នឹងអ្នកជំនួញដែលជាមេគ្រួសារ ? គេសម្គាល់បានដូចម្ដេចសិស្សមានរបៀបរៀបរយ ? ចូរទាញភាសិតខ្លះមកមើលក្នុងការមានរបៀប ។

* * * *

# មេរៀនទី៣៤. សំចៃ សន្សំទុកបំរុងការ បំណុល

## Economie, Epargne, Dettes

១– ការធ្វើខ្លួនឲ្យទៅជាអ្នកមានទ្រព្យសម្បត្តិ មិនមែនត្រឹមតែចេះរកស៊ីនោះទេ, គឺត្រូវឲ្យចេះចាត់ចែងទ្រព្យសម្បត្តិផង ដែលហៅថា សំចៃ ។

អធិប្បាយថា: អ្នកចេះសំចៃទ្រព្យសម្បត្តិ គឺចំណាយទ្រព្យសម្បត្តិទៅលើរបស់ណាដែលមានប្រយោជន៍ ហើយចេះចាយទៅតាមធនរបស់ខ្លួនដែលមានបាន គឺមិនត្រូវឲ្យខ្ជះខ្ជាយ ។ ការសំចៃជាការសំខាន់ក្នុងស្ថានភាព (situation) ដូចមេគ្រួសារគឺប្តីប្រពន្ធដែលជាមេផ្ទះ នោះត្រូវជាអ្នកចេះសំចៃ ។ ចំណែកឯប្តីក៏មានករណីយកិច្ចនឹងជួយទំនុកបំរុងប្រពន្ធខ្លួន ហើយមិនត្រូវចាយខ្ជះខ្ជាយឥតប្រយោជន៍នោះឡើយ ។ ឯកូនក៏ត្រូវប្រតិបត្តិតាមគោលនោះដែរ ។

២–មនុស្សសំចៃ ត្រូវជាអ្នកគិតវែងឆ្ងាយទៅអនាគត ហើយចេះសំចៃប្រាក់កាសទុកមួយអន្លើដែលកាលថ្ងៃ ដើម្បីការពារគ្រោះថ្នាក់ផ្សេងៗ និងពាស់ផកទៅធ្វើការពុំកើត ។

អធិប្បាយថា : សំចៃជាគុណសម្បត្តិមួយដ៏ល្អ ។ អ្នកដែលមិនសំចៃ បានប៉ុន្មានចាយប៉ុណ្ណោះ នោះតែងតែធ្លាក់ខ្លួនទៅជាអ្នកទ័លក្រលំបាក ជាអ្នករងទុក្ខយ៉ាងខ្លាំង ។

៣ - អ្នកដែលសំចៃទ្រព្យ នោះគ្មានបំណុលលើខ្លួនទេ ។ បំណុលជាចំណងមួយយ៉ាងសម្បើម ។ អ្នកណាមានបំណុល, អ្នកនោះឯងនឹងបានសេចក្តីទុក្ខលំបាក ។

អធិប្បាយថា : អ្នកជាប់បំណុលគេ តែងលុះក្នុងអំណាចម្ចាស់បំណុល ដែលជាពេជ្ឈឃាតខ្លួន (baurreau) អស់មួយជីវិត ទម្រាំដោះបំណុលរួច ។

៤ - ហេតុដូច្នេះ យើងគួរចំណាយតែក្នុងការដែលមានប្រយោជន៍ ព្រោះទ្រព្យសម្បត្តិអស់ទាំងនេះ តែងបានមកពីកេរ្តិ៍អាករម៉ែឪ ឬបានមកដោយកម្លាំងញើសដែលខំប្រឹងរកស៊ីខ្លួនឯង ។ អ្នកទាំងឡាយចូរជាអ្នកសំចៃ ។ ភាសិតបុរាណថា "តក់ ៗ គង់ពេញបំពង់, ព្រែកខ្វែងគួបគាបទឹងហៀរឡើងទៅជាស្ទឹងបាន" ។

*ចោទសួរ* ដូចម្ដេចហៅថាសំចៃ ហៅថាសន្សំទុកបំរុង ហៅថាខ្ជះខ្ជាយ? អ្នកយល់ដូចម្ដេចពីរឿងបំណុល? ក្មេងត្រូវចេះសន្សំទុកដាក់ដូចម្ដេច? បើនឹងត្រូវចំណាយ តើចំណាយបែបណា?

# មេសូត្រ

## ការចេះសំចៃមិនឲ្យជំពាក់បំណុលគេ

## សត្វរៃនិងស្រមោច

*បទកាកគតិ*

*ខែប្រាំងបងរៃ ច្រៀងលេងរាល់ថ្ងៃ សៀមមាត់តែយប់ តាំងពីព្រលឹម ទល់នឹងព្រលប់ ខ្សែខ្សេតឥតឈប់ ពុំទឹកស្រែកឃ្លាន ។ ដល់ខែរងា ធ្លាក់ខ្លួនវេទនា រកស៊ីអត់គ្មាន ទៅលោមដោច ។ ស្រមោចអ្នកមាន ថាខ្ញុំសូមទាន ខ្ញុំធនធានខ្លះ ។ សូមសន្យាមុន កន្ទើតផល្គុន ខ្ញុំមកដល់ផ្ទះ យកដើមទីនការ គ្រប់ពុំឲ្យខ្វះ សងជ្រះស្រឡះ ក្រោយមុខលែងខ្វី ។ ស្រមោចសួរវិញ ថាកាលប្រាំងមិញ រវល់ធ្វើអ្វី? រៃថាខ្ញុំច្រៀង ដាប្រក្រតី សូមប្រោសប្រណី អត់ទោសខ្ញុំផង ។ ស្រមោចថារៃ ល្អហើយអ្នកថ្ងៃ ឥត*

មានមោះហ្មង អ្នកប្រៀនកាលនោះ ពីព្រះគន្ធ ឥឡូវនេះម្ដង
ក៏ផងទៀតទៅ ។ ស្រមោចស្ដីហើយ ហើរចេញកន្ដើយ ទុកវៃឲ្យ
ទៅ ឈរជ្ពឹងសពាំង សញ្ជាប់ស្រុបសៅ ទឹកចិត្តមួយមៅ នឹងមារ-
យាទឯង ។ ព្រះសព្វញ្ញា ជាបរមគ្រូ ទ្រង់បានសំដែង ប្រាប់
ថាខ្លួនជា ទីពឹងខ្លួនឯង គឺខ្លួនត្រូវស្វែង រកទ្រព្យឲ្យខ្លួន ។

(កាព្យរបស់លោកឌុប សីនិម)

## ពន្យល់ពាក្យ

វៃ ន. សត្វស្លាបតូចៗ ពួកកណ្ដុរ នៅអាស្រ័យនឹងដើមឈើខ្ពស់ៗ; ចូលចិត្តបញ្ចេញសំឡេងក្រឡួសមាឪ; វៃបាយ, វៃកណ្ដឹងៗ សត្វនេះយំគ្រួសរំពងរន្ទាន់ស្រដៀងសូរកណ្ដឹងគួរឲ្យស្រណោះ ។

ស្រមោច ន. សត្វមួយយ៉ាង មានច្រើនពួកផ្សេងៗគ្នា ដោយមាឌសម្បុរប្រកាន់ខុសគ្នា ។

ខែប្រាំង ន. រដូវក្ដៅ, រដូវកំងមិនសូវមានភ្លៀងហៅ គិម្ហៈ ឬគិម្ហរដូវក៏បាន, មាន ៤ ខែរាប់ពីថ្ងៃ ១ កើតខែផល្គុនដល់ថ្ងៃ ១៥កើត

ខែអាសាឍ, មាន១១៨ថ្ងៃ; បើឆ្នាំដែលមានអធិកវារៈមាន ១១៩ ថ្ងៃ; ឆ្នាំដែលមានអធិកមាសមាន ៥ ខែ, ១៤៨ ថ្ងៃ ។

វេទនា ន. រងទុក្ខ, លំបាក ។

លោម កិ. និយាយសម្រួលចិត្តដោយសំដីទន់ ។

ធនធាន ន. ទ្រព្យរបស់ផ្សេង១ ដែលគង់នៅ ។

ក្រោយមុខ គុ. (សំដីបូរាណ) អនាគតកាល; ពេលវេលាក្រោយ ៗ ទៀត ឬខាងមុខតទៅទៀត ។ ក្នុងភាសាខ្មែរពិតមែនតែពាក្យក្រោយ មានន័យផ្ទុយនឹងពាក្យមុខ, ប៉ុន្តែក្នុងករណីយដែលត្រូវយកទៅប្រើប្រែកបសម្រាប់ហៅពេលវេលា ពាក្យទាំងពីរនេះទៅជាមានន័យស្របគ្នាទៅវិញ. ១- ថ្ងៃក្រោយ, បានសេចក្ដីដូចគ្នានឹងថ្ងៃមុខ (ផ្ទុយនឹងថ្ងៃមុន); ថ្ងៃបន្ទូក្រោយ ឬថ្ងៃបន្ទូខាងមុខផ្ទុយនឹងថ្ងៃបន្ទូមុន ... ។ ដូច្នេះហើយទើបបុរាណប្រើពាក្យក្រោយសំដៅសេចក្ដីថាពេលនៅក្រោយ ដែលមិនទាន់មកដល់ ឬពេលនៅខាងមុខដែលយើងមិនទាន់ទៅដល់ គឺក្នុងកាលអនាគត ។

ប្រាំងមិញ ន. វេលាក្ដៅដែលទើបនឹងផុតទៅ, វេលាប្រាំងមុននេះ ។ ពាក្យថា មិញ ប្រើនប្រើប្រែកបន្ទឹងពាក្យដែលហៅពេលវេលាឬវេលាផ្សេង ៗ បានសេចក្ដីថា ដែលទើបនឹងជាប់ផុតទៅមុននេះ ។. ព្រឹកមិញ, ល្ងាចមិញ ... ។

ផ្អើរអឺ កិ. គឺពាក្យសាមញ្ញ; ផ្អើរអឺ ។

ប្រក្រតី (អានថាប្រក់-ក្រ-ដី) ធម្មតា, តាមចំណាំ, តាមទម្លាប់ៗ

ប្រោសប្រណី កិ. អនុគ្រោះ, លោះលា, ពាក្យអង្វរសូមឱ្យគេអាណិតអាសូរ ។

ប៉ែ ! ទិ. ពាក្យភ្ញាក់មាត់ដោយអស្ចារ្យ, ដោយភ្ញាក់ ។

ស្ងប់ស្ងៀម កិ. ផ្ចង់មុខដោយកើតទុក្ខខ្លាំង ។

ព្រះសព្វញ្ញូ ន. លោកអ្នកត្រាស់ដឹងសព្វ, ព្រះពុទ្ធ ។

* * * *

## មេរៀនទី ៣៩ កំណាញ់, ខ្ជះខ្ជាយ, ល្បែងស៊ីសង

**Avarice, Prodigalité, Jeu**

១– កុំប្រឡូកការសន្សំ សំចៃ ទំនងសេចក្ដីកំណាញ់ ។ មនុស្ស

កំណាញ់ មិនមែនសន្សំទ្រព្យ ដើម្បីទុកធ្វើការអ្វីណាមានប្រយោជន៍ឲ្យទៅនោះទេ គឺសន្សំគ្រាន់ទុកជាការសប្បាយប៉ុណ្ណោះ ។

អធិប្បាយថា: មនុស្សកំណាញ់ តែងធ្វើខ្លួនឲ្យជាមនុស្សរងទុក្ខ ដោយការខ្វះខាត, ពិតតែមានទ្រព្យច្រើន, តែមនុស្សបែបនេះរស់នៅដូចជាអ្នកកំសត់ទុគ៌ត, មិនមែនជាអ្នកមានមនុស្សធម៌, ជាមនុស្សដែលគេតិះដៀល ។ មនុស្សកំណាញ់ ធ្វើខ្លួនឲ្យជាអ្នកកាន់សាសនាក៏ពុំបាន, ធ្វើខ្លួនឲ្យទៅជាមនុស្សទឹងគេស្ញើរតែពុំកើត ។ សេចក្តីកំណាញ់ជាទោសណាមក ១ យ៉ាងអាក្រក់ ។ ទោសនៃការកំណាញ់នេះ តែងជាប់រហូតដល់ស្លាប់ ។ ឯទោសដទៃ ៗ តែងដល់ចាស់ទៅ គង់មានគិតឃើញខ្លះ ហើយក៏កែខ្លួនទៅបាន ។ ឯមនុស្សកំណាញ់នោះ ចាស់ទៅរឹងរឹតតែកំណាញ់ខ្លាំងទៅទៀត ដូចមានឮល្បីឈ្មោះ អទិន្នបុព្វកព្រាហ្មណ៍ជាដើម ។

២- ការខ្ជះខ្ជាយ ក៏ប្រហែលគ្នានឹងការកំណាញ់ដែរ, គឺការចាយវាយឥតគិត ឥតពិចារណា ដោយដោរខ្វះ ដោយចិត្តរហ័សខ្វះ ដោយព្រហើនខ្វះ ។

អធិប្បាយថា: មនុស្សខ្ជះខ្ជាយ គឺជាមនុស្សស្រឡាញ់តែការតែល្អ ៗ គ្រឿងតាក់តែង ជាអ្នកខ្ជិល មិនស្គាល់តម្លៃរបស់ លុះតែចាយអស់ទើបភ្ញាក់ខ្លួន, ទុកដូចជាមនុស្សឆ្កួតអុជចង្កៀងកណ្ដាលថ្ងៃត្រង់ ដល់វេលាយប់រកប្រេងដុតគ្មាន ។

៣- អ្នកលេងល្បែងស៊ីសង រឹងរិតតែដួរជាតិទៅទៀត ជាទោស ១ ដ៏ធំគួរភ័យ នឹងធ្លាក់ទៅក្នុងគ្រោះថ្នាក់ណាមួយពុំខាន ។ មនុស្សលេងល្បែង ជាមនុស្សគ្មានបរិយាល្អ ជាមនុស្សមិនថ្លៃថ្នូរ ។ ប្រាក់បានមកពីល្បែង មិនឈ្មោះថាការសន្សំល្អទេ, យូរទៅហិនហោច, ព្រួយចិត្តជ្រួតគ្មានសង្ឃឹម បណ្ដាលទៅជាសម្លាប់ខ្លួនឯង ។

៤-ការកំណាញ់ មិនសូវធ្លាក់ទៅលើពួកក្មេងៗទេ ព្រោះក្មេងមិនទាន់ស្គាល់តម្លៃប្រាក់ ដូចជាមនុស្សចាស់ដែលបានមកពីកំលាំងញើស; ក្មេងច្រើនតែខ្ជះខ្ជាយ ។

ដូច្នេះអ្នកទាំងឡាយ, ចូរអ្នកកុំកំណាញ់ពេក កុំខ្ជះខ្ជាយហួសហេតុពេក កុំប្រព្រឹត្តផ្លូវល្បែងពេក តែត្រូវជាអ្នកចេះសំចៃ ។

ល្បែងនាំឲ្យខូចប្រយោជន៍ ៣ យ៉ាងគឺ: ខាតពេលវេលា,

ខាតប្រាក់កាស, ខូចសតិសម្បជញ្ញៈ ។

*ចោទសួរ*—ដូចម្ដេចដែលហៅថាកំណាញ់? មនុស្សកំណាញ់ប្រព្រឹត្តដូចម្ដេច? ដូចម្ដេចហៅថាមនុស្សខ្ជះខ្ជាយ? មនុស្សខ្ជះខ្ជាយនឹងទទួលគ្រោះថ្នាក់ដូចម្ដេច? ដូចម្ដេចបានជាល្បែងស៊ីសង ជាការនាំឲ្យមានគ្រោះថ្នាក់? បុត្ររបស់អ្នកកំណាញ់ប្រព្រឹត្តដូចម្ដេច? កូនរបស់មនុស្សខ្ជះខ្ជាយប្រព្រឹត្តដូចម្ដេច?

## ការអាន

## រឿងកំណាញ់ក្រៀតម្រា

មានព្រាហ្មណ៍ម្នាក់ឈ្មោះអទិន្នបុព្វកព្រាហ្មណ៍ នៅក្នុងនគរសាវត្ថី ។ បានជាឈ្មោះថាអទិន្នបុព្វកៈ ព្រោះព្រាហ្មណ៍នោះជាមនុស្សកំណាញ់កាញ់សម្បត្តិទុក មិនដែលបរិច្ចាគទ្រព្យចេញធ្វើបុណ្យឲ្យទាន ដល់សមណព្រាហ្មណ៍និងស្មូមយាចកទាំងឡាយឡើយ ។ ព្រាហ្មណ៍នោះមានកូនប្រុសម្នាក់ ឈ្មោះមដ្ឋកុណ្ឌលី ។ កូននោះចំរើនធំហើយ, អទិន្នបុព្វកព្រាហ្មណ៍ជាបិតា ប្រារព្ធនឹងធ្វើកុណ្ឌលជាគ្រឿងបំពាក់ឲ្យ ក៏គិតថានឹងទៅជួលជាងទងធ្វើ ក្រែងបង់ថ្លៃឈ្នួល, ទើបព្រាហ្មណ៍យកមាសមកដំដោយខ្លួនឯង ធ្វើជា

កុណ្ឌលមានគាពលើងឥតក្រាប់ ហើយបំពាក់ឲ្យកូននោះ ។ ហេតុដូច្នោះ ទើបកូននោះបាននាមឈ្មោះថា មដ្ឋកុណ្ឌលីកុមារ (ទៅកុណ្ឌលលើង) ។ លុះចំណេរតមក ទៅមដ្ឋកុណ្ឌលីនោះមានជម្ងឺឈឺគឺកេតស្គមស្លៀង ។ នាងព្រាហ្មណីនិយាយនឹងប្ដីថា កូនយើងកើតកេតស្លៀង គួរអ្នកទៅរកគ្រូពេទ្យមកមើលវា ។ ឯព្រាហ្មណ៍ជាអ្នកខ្វាចបង់ខាតទ្រព្យសម្បត្តិ គិតថា បើអញទៅរកគ្រូមកមើលនឹងបង់ទ្រព្យដោយតំនាប់គេផង ដោយអាហារផង, ព្រាហ្មណ៍គិតដូច្នេះហើយក៏ធ្វើព្រងើយ ។ លុះអាការកេតកូននោះប្រែខ្លាំងឡើងព្រាហ្មណ៍ទាល់គំនិត ទើបដើរទៅរកគ្រូតាមផ្ទះ ហើយក៏សួរពេទ្យថា អើអ្នកគ្រូថ្នាំ, បើគេកើតកេតស្លៀង ស៊ីពុំបាន ដេកពុំបាននៅតែឯណោះ ដូច្នេះតើគេប្រើថ្នាំយ៉ាងណា ?

ឯគ្រូថ្នាំបានឮអទិន្នបុព្វកៈសួរដូច្នោះ ក៏ប្រាប់តែផ្ដាសទៅថា យកឫសឈើនោះយកស្លឹកឈើនោះៗមក ស្ងោរឲ្យផឹកទៅចុះ ។ គ្រូប្រាប់ថ្នាំនោះគេយល់ថា ព្រាហ្មណ៍កំណាញ់ទ្រព្យ មិនហ៊ានអញ្ជើញគេទៅឲ្យមើលកូន ក្រែងបង់ថ្លៃថ្នាំថ្លៃអាហារ ទើបគេប្រាប់

ផ្តេសផ្តាសទៅ ៗ ឯអទិន្នបុព្វកព្រាហ្មណ៍ ឮគេប្រាប់ដូច្នោះ ក៏មករកជីកឫសឈើបេះស្លឹកឈើតាមបង្គាប់គ្រូ មកឲ្យផឹកមិនត្រូវសោះៗ កូននោះរឹងរិតតែឈឺឡើងៗ ៗ ព្រាហ្មណ៍ដឹងថាពេលនោះមើលមិនជាហើយ ទើបគិតថា កូនអញឈឺធ្ងន់ហើយ នឹងទុកឲ្យនៅក្នុងផ្ទះពុំបានក្រែងពួកញាតិមិត្តទាំងឡាយចូលមកសួរជម្ងឺ គេនឹងឃើញទ្រព្យសម្បត្តិអញ ហើយគេនឹងរកគួនខ្ចីសុំអញតទៅទៀត, បើដូច្នេះ មានតែលើកវាយកទៅដាក់ឯល្វែងតាកខាងក្រៅទើបផុតក្តីរំខាន, គិតហើយប្តីប្រពន្ធនាំគ្នាសែងត្រៃកូនចេញមកដាក់ឲ្យដេកនៅល្វែងក្រៅ ៗ ឯចៅមដ្ឋកុណ្ឌលីកុមារនោះ លុះពេលកំរើកខ្លាំងហើយក៏ដល់នូវកាលកិរិយាស្លាប់ ឰដ៏កាលនោះហោង ៗ

ឯជនទាំងពីរយល់កូនស្លាប់ហើយ ក៏តក់ទ្រូងយំសោកស្តាយដោយក្តីស្នេហាអាល័យបុត្រ នាំគ្នាយកសពបុត្រទៅដុតឯទីប៉ាឆាតាមប្រវេណីព្រាហ្មណ៍ ៗ

រឿងនេះបានសេចក្តីថា បុគ្គលមានទ្រព្យច្រើនមិនបានបំរើនប្រយោជន៍ដល់អ្នកដទៃ ឬអាស្រ័យខ្លួនឯង, ទ្រព្យនោះឯងប្រៀប

ដូចទឹកសមុទ្រច្រើនផុតវិស័យ តែសៅប្រៃមនុស្សផងអាស្រ័យផឹកស៊ី

ពុំបាន ។

## ពន្យល់ពាក្យ

អនិទ្ធបុត្តកព្រាហ្មណ៍ ន. "មនុស្សមិនធ្លាប់ឲ្យទាន" ។

តាក ន. របៀងខាងក្រោយផ្ទះ ។

ជម្ងឺរោគលឿង ន. ជម្ងឺឈឺហត់ សាច់ឡើងស្លាំង សម្បុរលឿង។

កាលកិរិយា ន. ស្លាប់ ។

សាវត្ថី ន. នាមក្រុងក្នុងមជ្ឈិមប្រទេស (ឥណ្ឌា) ។

ប្រាប់ផ្ដេសផ្ដាស ប្រាប់មិនចំ, ប្រាប់តាមតែបាន, ប្រាប់តាម

តែនឹកឃើញ ។

សព ន. ខ្មោចស្លាប់, សពលោកសង្ឃ ។

ប៉ាឆា ន. ទីកប់ខ្មោច, ទីដុតខ្មោច ។

# មេរៀនទី ៣៦ ករណីយកិច្ចចំពោះសត្វ

## **Devoirs envers les animaux**



១- សត្វទាំងឡាយ បានហុចប្រយោជន៍សំខាន់ជាច្រើនមកឲ្យមនុស្ស បានជួយបំពេញភោគសម្ប័ទដល់មនុស្សលោក ។ ដូច្នេះមនុស្សត្រូវមានករណីយកិច្ចចំពោះសត្វទាំងអស់នេះ ។

អធិប្បាយថា: វិចារណញ្ញាណនឹងសេរីរបស់មនុស្ស អាចធ្វើមនុស្សលោកឲ្យទៅជាស្ដេចធំក្នុងលោកសន្និវាសបាន ។ សព្វសត្វទាំងអស់សុទ្ធតែនៅក្រោមអំណាចមនុស្ស ។ តែមនុស្សយើងមិនត្រូវតាំងខ្លួនជាស្ដេចអសប្បុរស ឥតមេត្ដាករុណានោះទេ ។ ត្រូវតាំង

ខ្លួនឲ្យល្អចំពោះសត្វបំរើឬសត្វជាមិត្រសម្លាញ់ ។ កុងការដែលជាប្រយោជន៍របស់មនុស្ស, មនុស្សត្រូវមានសម្បជញ្ញៈ ត្រូវថែរក្សាចិញ្ចឹមសត្វដោយអាហារថ្នាំសង្កូវ មិនត្រូវធ្វើទុក្ខទោសដល់សត្វទាំងឡាយនោះឡើយ ។

២— មនុស្សយើងមិនត្រូវធ្វើបាបសត្វបម្រើដែលជាសត្វឥតគ្រឿងការពារ ដោយអំណាចឃោរឃៅនោះឡើយ, ព្រោះសត្វទាំងឡាយនេះ ក៏មានការដឹងគុណ ការឈឺចាប់ ដូចមនុស្សយើងដែរ, មិនចេះត្អូញត្អែរក៏ពិតមែន តែមានសេចក្ដីវេទនា ដោយមនុស្សលោកធ្វើបាប ។

អធិប្បាយថា : សត្វដែលយើងមានមេត្តាចំពោះវា វាតែងមានសេចក្ដីស្នេហាចំពោះម្ចាស់វិញ, ដូចសត្វឆ្កែដែលនៅថែទាំចាំផ្ទះយើងពាំពេលយប់ដែលយើងគេយកទឹកដោះឬកាត់យកពេម ក៏យើងត្រូវមេត្តាករុណាស្រឡាញ់វា ។ មានអ្នកខ្លះធ្វើបាបសត្វដែលកំពុងឈូសរេះដោយបន្ទុកធ្ងន់ ហើយគ្នាអូសទៅដោយលំបាក; ធ្វើយ៉ាងនេះជាការមិនល្អ ។ ប្រទេសយើងបានបញ្ញត្តច្បាប់អំពីរឿងនេះ ។

៣– មនុស្សមានអំណាចសម្លាប់សត្វដើម្បីជាអាហារខ្លួនក៏ពិតមែន, តែបើគិតឲ្យត្រូវទៅ អាហារមិនមែនមានតែប៉ុណ្ណោះទេ, មនុស្សយើងអាចចិញ្ចឹមជីវិតដោយសារផលនៃរុក្ខជាតិ ទីងតិណជាតិផ្សេងៗ មានស្រូវដំឡូងជាដើម ដែលជាអាហាររបស់មនុស្សដែរនោះក៏បាន ។

អធិប្បាយថា: សត្វណាដែលកាចសាហាវ ឬបំផ្លាញផលដំណាំ ក៏គួរតែការពារចំពោះសត្វនោះ ដោយអាជ្ញាផ្សេងៗ ។ តែយើងមិនត្រូវធ្វើទុក្ខទោសវាដោយការឥតប្រយោជន៍នោះទេ ។ ហេតុដូច្នេះ កុមារទាំងឡាយ មិនត្រូវធ្វើបាប កាត់ជើងឬស្លាបសត្វ កង្កែបគីង្គក់ ឬកន្ទុំរុយជាដើម ដោយការលេងសប្បាយ ឬធ្វើសត្វឲ្យមានសេចក្ដីតក់ស្លុតភិតភ័យនោះឡើយ ទាំងមិនត្រូវបំផ្លាញសំបុកសត្វ ឬយកពងវាឡើយ ។ កូនក្មេងដែលទំលាប់ធ្វើបាបសត្វយ៉ាងនេះ, ដល់ធំឡើងក៏ទៅជាមនុស្សកោងកាច ចិត្តអាក្រក់ទីងមិត្រភក្តិរបស់ខ្លួន ។ ត្រូវតែមានសេចក្ដីមេត្តាករុណាចំពោះសត្វទាំងឡាយនេះជាដរាប ។

# ការអាន

សត្វឆ្កែ មិនមែនគ្រាន់តែជាសត្វស្មោះត្រង់នឹងម្ចាស់នោះទេ, ជាសម្លាញ់មួយយ៉ាងស្និទ្ធស្នាលរបស់ម្ចាស់ រហូតដល់ទៅស៊ូប្តូរជីវិតជាមួយនឹងម្ចាស់ ។

មានសេចក្តីដំណាលថា ក្នុងក្រុងកោសម្ពី (ឥណ្ឌា) មានបុរសម្នាក់ឈ្មោះគោបាល (គង្វាលគោ) ។ មានឆ្កែមួយចេះដឹងពន់ពេកជាទីស្រឡាញ់របស់គាត់ ។ គាត់បាននិមន្តព្រះបច្ចេកពុទ្ធឲ្យមកទទួលភត្តឯផ្ទះគាត់រាល់ថ្ងៃ ។ វេលាថ្ងៃមួយ គាត់បានទៅនិមន្តព្រះបច្ចេកពុទ្ធដោយបានយកសុនខរបស់គាត់នេះជាប់ទៅជាមួយផង ។ វេលាណាដល់ព្រៃ គាត់ក៏យកដំបងវាយព្រៃបីដង ដើម្បីដេញម្រឹគពាលសាហាវ ។ សុនខនោះក៏ព្រុះក្នុងទីដែលមានសត្វសាហាវ ហើយក៏ដើរតាមម្ចាស់រហូតដល់អាស្រមព្រះបច្ចេកពុទ្ធ ។ លុះដល់អាស្រមនាយគោបាលជាម្ចាស់ ក៏បានទូលព្រះបច្ចេកពុទ្ធថា ខ្ញុំព្រះករុណាមានកិច្ចការរវល់ច្រើន ហេតុនេះដល់ទៅថ្ងៃមុខ ខ្ញុំព្រះករុណានឹងប្រើសុនខនេះ ឲ្យមកនិមន្តជំនួស, បើឃើញសុនខនេះ

មកដល់, សូមនិមន្តទៅជាមួយដោយមេត្តា ៗ ថ្ងៃក្រោយតមក នៅពេលដែលកត្តរៀបចំស្រេចហើយ. នាយគោបាលក៏ប្រើសុនខនោះឲ្យទៅនិមន្តព្រះបច្ចេកពុទ្ធ ៗ សុនខបានទទួលពាក្យហើយ ក៏បោលទៅព្រះតាមផ្លូវដែលមានសត្វម្រឹគសាហាវ, លុះដល់ទៅអាស្រមព្រះបច្ចេកពុទ្ធ ក៏ព្រុះឲ្យសញ្ញា ៗ ព្រះបច្ចេកពុទ្ធជ្រាប ក៏និមន្តចុះមកដើរតាមឆ្កែរហូតដល់ផ្ទះ ៗ លោកតែងតែនិមន្តតាមឆ្កែរៀងរាល់ថ្ងៃ ៗ មានថ្ងៃមួយ នៅវេលាដែលនិមន្តតាមឆ្កែមក ដល់ផ្លូវបែកមួយ លោកធ្វើជានិមន្តឲ្យខុសពីផ្លូវដែលឆ្កែនោះនាំ ៗ សុនខឃើញដូច្នោះក៏ស្ទុះទៅខាំជាយចីពរឲ្យនិមន្តមកតាមផ្លូវទៅផ្ទះរបស់ខ្លួនវិញ ៗ ថ្ងៃងពីព្រះបច្ចេកពុទ្ធដែលគង់នៅទីនោះយូរផង ថែមទាំងមានចោរដោច់ដាចផង ក៏ចង់និមន្តទៅទីឯទៀតដើម្បីស្វែងរកចីវរ, ក៏បានលានាយគោបាលចេញពីទីនោះ ៗ នៅវេលាដែលចេញទៅ សុនខក៏បានជូនព្រះបច្ចេកពុទ្ធទៅដល់ផ្លូវឆ្ងាយបន្តិច, លោកក៏បានដេញឆ្កែនោះឲ្យត្រឡប់ទៅវិញ, ប៉ុន្តែសុនខដែលជាប់សេចក្ដីស្នេហាទីនព្រះបច្ចេកពុទ្ធ ពុំព្រមត្រឡប់វិញឡើយ, លុះព្រះបច្ចេកពុទ្ធហោះឮង៍

អាកាសទៅ, ដ្បិតព្រះដោយសេចក្ដីអាល័យស្រឡាញ់ ក៏បែកបំពង់កស្លាប់នៅទីនោះ ហើយបានទៅកើតឯស្ថានសួគ៌ មានឈ្មោះថ្មោកជាឃោសកទេវបុត្រ ។

## ពន្យល់ពាក្យ

**សុនខ** ន. សត្វចតុប្បាទ ជាសត្វស្រុក ច្រើនមានសេចក្ដីស្នេហាចំពោះម្ចាស់ ។

**បច្ចេកពុទ្ធ** ន. ព្រះបន្ទាប់ ត្រាស់ដឹងម្នាក់ឯងមិនបានទូន្មានគេពល់គ្នាផងទេ ។

**កោសម្ពី** ន. នាមក្រុងមួយនៅក្នុងមជ្ឈិមប្រទេស ។

**អាស្រម** ន. ផ្ទះតូចធ្វើនៅក្នុងព្រៃហៅថាតូបក៏បាន ។

**ស្នេហ** ន. សេចក្ដីស្រឡាញ់ ។

**ឃោសកទេវបុត្ត** ន. នាមទេវតាមួយអង្គនៅស្ថានសួគ៌ ដែលសោយផលជាទិព្វ ដោយបានបំពេញបុញ្ញកម្មល្អ ពីកន្លងស្ថានមនុស្សលោកទៅ ។

# ការអាគ

កុមារទាំងឡាយចូរជាអ្នកកុំធ្វើចិត្តអាក្រក់នឹងសត្វធាតុ, ដ្បិតសត្វទាំងនេះទុកដូចជាអ្នកជួយកម្លាំងយើង ជាខ្ញុំកំដរក្នុងផ្ទះនឹងក្រៅផ្ទះ ជាមិត្រភក្តិរបស់យើង ៗ អ្នកទាំងឡាយត្រូវស្រឡាញ់ហើយទុកសត្វនេះ ដូចជាបងប្អូន ៗ សត្វឆ្កែឆ្មា ថែរក្សាផ្ទះយើង. សត្វគោក្របីសេះ ។ល។ ជួយបន្ទុរកម្លាំងយើង ក្នុងការកសិកម្មនឹងពាណិជ្ជ-កម្ម, កង្កែប គីង្គក់ ចាប ។ល។ ជួយថែរក្សាដំណាំយើង ៗ សត្វអស់ទាំងនេះ ជាភ្នាក់ងារដ៏សំខាន់របស់មនុស្ស ៗ ដូច្នេះកុមារទាំងឡាយគួរកុំប្រមាថធ្វើទុក្ខបុកម្នេញដល់សត្វដែលគ្មានគ្រឿង តបតការពារនឹងយើងឡើយ ៗ មិនត្រូវពង្រាត់បម្រាសពងនឹងកូនតូចៗរបស់វា អំពីមេវាឡើយ ៗ មានសេចក្ដីដំណាលថា ថ្ងៃមួយមានសត្វចាបមួយដែលសត្វខ្លែងដេញចាប, ក៏វាហើរសំដៅចូលមកជ្រកកោននៅក្នុងដៃតាបសឥសីម្នាក់ ដែលមានអាស្រមនៅក្នុងព្រៃ ដោយសេចក្ដីតក់ស្លុតនឹងខ្លែង ៗ តាបសឥសីក៏លាក់សត្វចាបនោះដែលកំពុងភ័យញ័រគត្រនក្នុងចីពរ ហើយលោកក៏បានពោលពាក្យផ្អែមល្ហែមទៅនឹងសត្វនោះថា: ឯងជាសត្វខ្សោយ, យើងត្រូវតែជួយសង្គ្រោះឯង ៗ

ចោទសួរ ហេតុដូចម្ដេចបានជាមនុស្សត្រូវមានករណីយកិច្ចចំពោះសត្វ? កិច្ចទី ១ របស់មនុស្សចំពោះសត្វដូចម្ដេចខ្លះ? ដូចម្ដេចក៏មិនត្រូវធ្វើទុក្ខបុកម្នេញដល់សត្វ? សត្វដែលគេធ្វើទុក្ខបុកម្នេញដល់នូវសេចក្ដីវេទនាលំបាក ដូចម្ដេចទៅ? មនុស្សសម្លាប់សត្វបានតាមអំពើចិត្តឬ? កាលណាទើបត្រូវសម្លាប់បាន? សត្វជាអ្វីនឹងមនុស្ស? បើគ្មានសត្វ តើមនុស្សបានការស្រួលលំបាកដូចម្ដេចក្នុងការងារផ្សេងៗ?

## ការហាត់បញ្ជាក់ឡើងវិញ

## កិច្ចការដាក់ឲ្យធ្វើ

១– ចូរពន្យល់ភាសិតដូចតទៅនេះ "សេចក្ដីខ្ជិល នាំមកនូវការលំបាក; សេចក្ដីឧស្សាហ៍ធ្វើការនាំមកនូវការស្រួល" ។

២– អ្នកមានបំណងនឹងបន្ដវិជ្ជារបស់អ្នកតទៅទៀត, កូនអ្នកម្នាក់ដែលកំពុងរៀនធ្វើជាកម្មករ មានចិត្តចង់យកតម្រាប់អ្នក; ចូរអ្នកសរសេរសំបុត្រទៅពន្យល់កូនអ្នកថា "កិច្ចការរកស៊ីទាំងឡាយ សឹងសុទ្ធតែជាអំពើគួរ ហើយនឹងត្រូវធ្វើការងារនោះឲ្យហ្មត់ចត់" ។

៣– ថ្ងៃអាទិត្យដែលជាថ្ងៃឈប់សម្រាកជិតមកដល់ហើយ ចូរអ្នកអធិប្បាយអំពីសេចក្ដីសប្បាយផ្សេងៗដែលអ្នកបម្រុងនឹងសេព ។